**BMI0042**

**សម្ភាសន៍ជាមួយឈ្មោះ ទៀប យុន ភេទប្រុស អាយុ៥៧ឆ្នាំ**

**មុខងារនៅសម័យខ្មែរក្រហមៈ យោធាខ្មែរក្រហមប្រចាំកងពលទី១ ខេត្តបាត់ដំបង**

**មុខងារបច្ចុប្បន្នៈ កសិករ**

**ស្រុកកំណើតនៅភូមិគោកឃ្មុំ ឃុំគោកឃ្មុំ ស្រុកបាត់ដំបង ខេត្តបាត់ដំបង**

**សព្វថ្ងៃរស់នៅភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ ហ៊ិន សុធានី**

**០១:១៩:២៤**

**៤១ទំព័រ**

ធានី : ថ្ងៃនេះទី១៩ ខែតុលា ឆ្នាំ២០១០ ។ ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចុះមកនេះចង់សាកសួរពូពីប្រវត្តិរបស់ពូដែលបានឆ្លងកាត់រហូតមកដល់ស្រុកម៉ាឡៃ រហូតមកដល់ឥឡូវទៀត ។ តើការរស់នៅរបស់ពូយ៉ាងម៉េច មានការលំបាកយ៉ាងម៉េចខ្លះ ហើយរឿងរ៉ាវដែលពូប្រាប់ខ្ញុំ ខ្ញុំយកទៅធ្វើជាសៀវភៅ និងសម្រាប់ក្មេងៗ ឬអ្នកសិក្សាផ្សេងៗគាត់ចង់ដឹងស្រាវជ្រាវ ។ ពូអនុញ្ញាតិឲ្យខ្ញុំយកបទសម្ភាសន៍នេះសម្រាប់ធ្វើជាសៀវភៅបានទេ?

យុន : មានអី ។

ធានី : ហើយខ្ញុំសុំថតជាសម្លេង ក៏ដូចជារូបថតរបស់ពូយកទៅប្រើប្រាស់បានទេ?

យុន : បាន ។

ធានី : លោកពូមានឈ្មោះអីដែរ?

យុន : ខ្ញុំឈ្មោះ ទៀប យុន ។

ធានី : ឆ្នាំនឹងពូអាយុប៉ុន្មាន?

យុន : ខ្ញុំកើតឆ្នាំ១៩៥៣ ។

ធានី : មកដល់ឥឡូវ?

យុន : ៥៧ ។

ធានី : ពូមានស្រុកកំណើតនៅណា?

យុន : ខ្ញុំនៅភូមិគោកឃ្មុំ ឃុំគោកឃ្មុំ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ធានី ៖ កាលពីសម័យនឹងគេដាក់អីចឹង?

យុន ៖ បាទ!

ធានី ៖ សព្វថ្ងៃពូរស់នៅកន្លែងណាដែរ?

យុន ៖ ខ្ញុំរស់នៅភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឪពុកពូឈ្មោះអីគេ?

យុន ៖ ឪពុកខ្ញុំឈ្មោះ យ៉ាន់ ។

ធានី ៖ អីគេយ៉ាន់?

យុន ៖ មិនសូវដឹងដែរ បើខ្ញុំដាក់មិនដែលបាននេះផង បើជីតាគាត់នឹងខ្ញុំអត់ដឹង ដឹងតែពុកគាត់ ។

ធានី ៖ គាត់នៅរស់ទេ?

យុន ៖ គាត់នៅភូមិធ្លា ជិតស្រែត្រែងដែរ ។

ធានី ៖ ឃុំអីគេ?

យុន ៖ ឃុំស្រែត្រែង ។

ធានី ៖ ស្រុកអីគេ?

យុន ៖ ស្រុកថ្មគោល ។

ធានី ៖ ខេត្តបាត់ដំបង ។ ម្តាយពូឈ្មោះអីគេ?

យុន ៖ ខ្វាន់ ។

ធានី ៖ អីគេខ្វាន់?

យុន ៖ ខ្ញុំអត់ដឹង ។

ធានី ៖ គាត់នៅរស់ទេ?

យុន ៖ នៅរស់ ។

ធានី ៖ រស់នៅជុំជាមួយគ្នា?

យុន ៖ នៅជុំគ្នាគាត់ ។

ធានី ៖ ពូមានបងប្អូនប៉ុន្មាននាក់?

យុន ៖ បងប្អូន៩នាក់ ។

ធានី ៖ នៅរស់ទាំងអស់?

យុន ៖ ស្លាប់អស់ប៉ុន្មាននាក់ ៣នាក់ ។

ធានី ៖ សល់៦?

យុន ៖ បាទ!

ធានី ៖ បងប្អូនស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យុន ៖ ប្រុស៤នាក់ ស្លាប់ម្នាក់នៅសល់៣នាក់ ។

ធានី ៖ ប្រុស៤ ស្រី៥ តែស្លាប់ម្នាក់ទេ?

យុន ៖ បាទ! ស្លាប់ម្នាក់ ហើយស្រីមួយទៀត ។

ធានី ៖ អីចឹងស្លាប់តែ២មិនមែន៤ទេ?

យុន ៖ រកនឹកសិន អូ!ស្លាប់តែខ្ញុំអត់បានទៅទេ ម្នាក់ស្រីដែរ ទៅបានប៉ុននឹងឯង ។

ធានី ៖ គាត់ស្លាប់ពេលណាបងប្អូនពូ?

យុន ៖ ទើបស្លាប់ឥឡូវ កាលពីឆ្នាំ២០០០ ។

ធានី ៖ ស្លាប់ឥឡូវទាំងអស់គ្នា ទាំងស្រីប្រុសនឹង?

យុន ៖ បាទ!

ធានី ៖ ពូមានឈ្មោះហៅក្រៅទេ?

យុន ៖ ឈ្មោះហៅក្រៅនឹង ហ្នឹងហើយឈ្មោះខ្ញុំ ។

ធានី ៖ ឈ្មោះទៀប យុននឹង?

យុន ៖ បាទៗ ។

ធានី ៖ ចុះអត់មានឈ្មោះហៅក្រៅ?

យុន ៖ អត់មានទេ ។

ធានី ៖ ចុះឈ្មោះបដិវត្ត?

យុន ៖ អត់មាន ។

ធានី ៖ ពូរៀនដល់ទីប៉ុន្មានដែរ?

យុន ៖ ខ្ញុំអត់រៀនផង ។

ធានី ៖ ពូអាចអានអក្សរបាន?

យុន ៖ មើលបានខ្លះ ។

ធានី ៖ ពូរៀននៅណាវិញ?

យុន ៖ ខ្ញុំកាលពីសម័យនឹង ខ្ញុំមិនបានរៀនជ្រៅជ្រះនឹងគេអី ខ្ញុំទៅនៅវត្តខ្ញុំរៀនតែស្រះហ្នឹងហើយ ដល់នេះខ្ញុំចេះរៀនបន្តប់ចេះមើលរួច សរសេរបាន ។

ធានី ៖ រៀនខ្លួនឯង?

យុន ៖ បាទ!

ធានី ៖ រៀននៅវត្តណាកាលនឹង?

យុន ៖ នៅវត្តតាជិត ។

ធានី ៖ វត្តនឹងនៅកន្លែងណា?

យុន ៖ គេហៅវត្តតាជិតនៅបាត់ដំបងនៅទីក្រុងនឹង ។

ធានី ៖ វត្តតាមឹម?

យុន ៖ អត់ទេ តាមឹមនៅក្រោមឆ្ងាយ ។

ធានី ៖ នៅក្បែរវត្តដំរីស?

យុន ៖ ហ្នឹងហើយជិតគ្នានឹង ។

ធានី ៖ ពូអាចជួយរៀបរាប់បានទេ ពីដំបូងមកអ៊ីដែលពូបានឆ្លងកាត់ម៉េចបានពូមកដល់ម៉ាឡៃ?

យុន ៖ ខ្ញុំរស់នៅក្រោមការដឹកនាំគេ នៅកងទ័ពគេបញ្ជូនមក ខ្ញុំមក ។

ធានី ៖ ដំបូងពូនៅស្រុកកំណើត?

យុន ៖ បាទ!

ធានី ៖ ម៉េចបាន?

យុន ៖ អានឹងខ្ញុំចេញកាលពីសម័យនឹងឆ្នាំ៧២ ខ្ញុំចេញតស៊ូ ។

ធានី ៖ តស៊ូធ្វើអីគេ?

យុន ៖ ខ្ញុំធ្វើកងទ័ព ។

ធានី ៖ កងទ័ពនៅណា?

យុន ៖ នៅខេត្តបាត់ដំបងនៅកំពីងពួយ ។

ធានី ៖ ម៉េចទៀត?

យុន ៖ មិនដឹងម៉េច ។

ធានី ៖ ពេលពូនៅកងទ័ពនៅកំពីងពួយនឹងនៅធ្វើអីគេ?

យុន ៖ នៅធ្វើទ័ពនៅនឹង ទៅវៃនឹងសមរភូមិកាលនឹងវៃរំដោះឆ្នាំ៧៥ ។

ធានី ៖ ពូមកវៃនៅសមរភូមិនៅណា?

យុន ៖ នៅបាត់ដំបង នៅបរវេលអី ។

ធានី ៖ នៅណាទៀត?

យុន ៖ ច្រើនកន្លែង ថាមិនអស់ ។

ធានី ៖ វៃពីបាត់ដំបងនឹងពីណាទៅណែ?

យុន ៖ ពេលកាលនឹងសម័យនឹងខ្ញុំធ្វើវៃសមរភូមិតូចៗ វៃឆ្លប់ធ្វើរំខានខ្មាំងចូលរុករានទៅតំបន់រំដោះយើង ការពារតំបន់រំដោះរហូតដល់ឆ្នាំ៧៥ យើងរំដោះ ។

ធានី :	កាលវៃ៧៥ពូនៅកន្លែងណា?

យុន :	ខ្ញុំចូលនៅថ្មគោល ។

ធានី :	ពូអត់បានឡើងដល់ទីក្រុងនឹងគេទេ?

យុន :	បាទ! អត់បានទេ ។

ធានី :	ពេលពូចូលធ្វើទាហានដំបូងមានបានហាត់រឹករឺនទាហានអីទេ?

យុន :	ខ្ញុំបានរៀនដែរ រៀនហាត់ពីរបៀបបច្ចេកទេសសគ្រាម ។

ធានី :	ហាត់ប៉ុន្មានខែ?

យុន :	ហាត់៦ខែ ។

ធានី :	អ្នកណាគេអ្នកបង្ហាត់?

យុន :	លោកវរសេនាធំខ្ញុំឈ្មោះ ណាំ ។

ធានី :	បន្ទាប់មកទៀត ពូទៅណាទៀតទៅ?

យុន :	ពេលរំដោះហើយឆ្នាំ៧៥នឹង ខ្ញុំគេឲ្យនៅថ្មគោល ហើយទៅស្លុងជាមួយប្រជាជននៅភូមិវាលទ្រា ជាមួយកងចល័ត១៧មេសា ។

ធានី :	វាលទ្រា ថ្មគោលដែរ?

យុន :	បាទ!

ធានី :	ពេលពូមកដល់ជាមួយកងចល័តហើយ?

យុន :	បាទ! ឆ្នាំ៧៥រហូតមកដល់ឆ្នាំ៧៨គេឲ្យខ្ញុំមកវៃពួកខ្មែរសេរីនៅតំបន់ម៉ាឡៃនឹង ។

ធានី :	នៅម៉ាឡៃមានខ្មែរសេរី?

យុន :	បាទ!

ធានី :	មកពីណាវិញខ្មែរសេរីនឹង?

យុន :	អ្នកដែលចេញតស៊ូ ពួកខ្មែរសេរីដែលគេចពីខ្មែរក្រហមឆ្នាំ៧៥នឹង មកនៅដីថៃ ។

ធានី :	គាត់នឹងជាអ្នកណាគេដឹងទេ?

យុន :	ខ្ញុំមិនដឹងដែរ ប៉ុនរស់នៅក្រោមបញ្ជាគេៗឲ្យមកចេះមកៗ ។

ធានី :	មកម៉ាឡៃតាំងពីដំបូង?

យុន :	អឺ! ដល់រហូតមកវៃនឹងហើយ ឡប់ទៅវិញគេដកពួកខ្ញុំទៅនៅកងចល័ត ដកកាំភ្លើងដកអីអស់ ។ ទៅនៅកងចល័តបាន៣ខែ បានឆ្នាំ៧៦ខែ៤នឹងគេ ។

ធានី :	មុនដំបូងពូថាឆ្នាំ៧៨វៃខ្មែរសេរី?

យុន :	អូ! អា៧៨នឹង ពេលវៃនឹងហើយ ខ្ញុំនិយាយហួស ។ ទៅនោកងចល័តនៅសាយសាម៉ននឹង

ធានី : ហ្នឹងឆ្នាំ៧៦?

យុន : បាទ! រហូតគេបំពាក់កាំភ្លើងឲ្យមកវ៉ៃនៅពួកខ្មែរសេរីនឹងឯង ។

ធានី : ឆ្នាំ៧៥ នៅថ្មគោល នៅភូមិទ្រានឹង ធ្វើស្រែជាមួយកងចល័ត?

យុន : បាទ!

ធានី : ដល់៧៦ ធ្វើកងចល័តដែរ?

យុន : ៧៦ នឹងគេដក ។

ធានី : លែងធ្វើទាហានហើយ?

យុន : ហ្នឹងហើយ គេដកកាំភ្លើងអស់ហើយ ។

ធានី : ពូនៅធ្វើកងចល័តវិញ?

យុន : បាទ! កងចល័ត ដល់ហើយគេបំពាក់កាំភ្លើងឲ្យមកវ៉ៃនេះ ។

ធានី : នៅឆ្នាំ៧៨?

យុន : បាទ! វ៉ៃហើយឡប់ទៅវិញ ខ្ញុំត្រូវរបួសពិការទៅ ខ្ញុំនៅមន្ទីរពិការ ដល់រហូតឆ្នាំ៧៩មក គេហៅឲ្យគេប្រមូលប្រជាជនកងទ័ពឲ្យមកនឹង ខ្ញុំក៏មកតាមគេនឹងទៅ ។

ធានី : ៧៥ នៅថ្មគោលនៅស្ទូងស្រូវនឹង ពូនៅជាទាហានទេ អត់ទាន់រំសាយទេ?

យុន : បាទ! ទាហាន ។

ធានី : អ្នកណាគេមេរបស់ពូ?

យុន : ឈ្មោះ ណាំនឹង ។

ធានី : ណាំ វរសេនាធំនឹង?

យុន : ហ្នឹង ។

ធានី : លើណាំនឹងអ្នកណាគេ?

យុន : មានតាវ៉ននឹងកងពល ។

ធានី : ប្រធានកងពលទី១?

យុន : បាទ!

ធានី : នៅនឹងគេហៅកងពលទី១?

យុន : បាទ!

ធានី : កងពលទី១ ប្រចាំអីដែរ?

យុន : ប្រចាំភូមិភាគនឹង ។

ធានី : ភូមិភាគអីគេ?

យុន ៖ ភូមិភាគពាយ័ព្យ ។

ធានី ៖ ហើយកងពលនឹងគេធ្វើការអីគេ នារគេ?

យុន ៖ មុខនារគេគ្រប់គ្រងកងទ័ព ។

ធានី ៖ ដូចថាកងពលទី១សម្រាប់ធ្វើអី?

យុន ៖ និយាយពីទាហាននឹងសម្រាប់ដើរធ្វើការតាមភូមិ ជួយធ្វើការប្រជាជនស្ទូងដក ច្រូតស្រូវ ។

ធានី ៖ ពូដឹងថាអ្នកណាគេប្រធានធំលើវ៉ែន?

យុន ៖ ខ្ញុំអត់ដឹងទេ ។

ធានី ៖ ចុះណាគៈភូមិភាគ ពូថាមិញភូមិភាគពាយ័ព្យ?

យុន ៖ បាទ! ភូមិភាគពាយ័ព្យនឹងតារស់ ញឹម ។

ធានី ៖ ពូធ្លាប់ឃើញគាត់ទេ?

យុន ៖ ខ្ញុំមិនដែលឃើញទេ ខ្ញុំឮតែគេថាពេលដែលគេប្រជុំរៀនសូត្រទ័ព គេប្រកាសប្រាប់ខ្ញុំចាំបាន
អីចឹង ។

ធានី ៖ កាលនឹងពូធ្វើអីគេបានរៀនសូត្រធ្វើទ័ព?

យុន ៖ ខ្ញុំកងតូច ។

ធានី ៖ ប្រធានកងតូច?

យុន ៖ បាទ!

ធានី ៖ ប៉ុន្មាននាក់ ម៉ាកងតូចពូ?

យុន ៖ ម៉ាកងតូចវាមាន៣នាក់ ។

ធានី ៖ មានប្រធានកងធំ?

យុន ៖ កងធំលើនឹង កងធំបន្ទាប់ពីកងវរៈ ។

ធានី ៖ ចុះប្រធានកងតូចពូម៉េចមានតែនាក់?

យុន ៖ មាន៣នាក់នឹង មានប្រធាន អនុប្រធាន សមាជិក ។

ធានី ៖ ប៉ុន្មានកងតូចបានធំតទៀត?

យុន ៖ វា៣កងតូច បានអនុសេនាធំ ។

ធានី ៖ អនុសេនាតូច ឬធំ?

យុន ៖ ៣កងតូចគេហៅម៉ាកងធំ អានឹងគេហៅអនុសេនាធំ ។

ធានី ៖ ចុះអនុសេនាតូច?

យុន ៖ អនុសេនាតូចម៉ាកងតូច ។

ធានី ៖ ពូនឹងកងតូចមាន៣នាក់នឹង?

យុន ៖ បាទ! ក្នុង៣នាក់នឹងគ្រប់គ្រងកម្លាំង៣០នាក់ ។

ធានី ៖ បានន័យថាពូគ្រប់គ្រងអនុសេនាតូចនឹងមាន៣០នាក់ ៣នាក់នឹងមានប្រធាន អនុប្រធាន និង សមាជិក?

យុន ៖ បាទៗ ។

ធានី ៖ ពូជាអីគេក្នុង៣នាក់នឹង?

យុន ៖ ខ្ញុំប្រធាន ។

ធានី ៖ ប្រធានអនុសេនាតូចហៅកងតូច?

យុន ៖ កងតូច ។

ធានី ៖ អនុប្រធានពូឈ្មោះអីគេ?

យុន ៖ ឈ្មោះ នី ។

ធានី ៖ ស្រី ឬប្រុស?

យុន ៖ ប្រុស ។

ធានី ៖ ចុះបន្ទាប់មកទៀត?

យុន ៖ ឈ្មោះវ៉ន ។

ធានី ៖ ប្រុសដែរ?

យុន ៖ ប្រុសដូចគ្នា ។

ធានី ៖ ហ្នឹងសមាជិក?

យុន ៖ អឺ!

ធានី ៖ បន្ទាប់ទៀតម៉េចបានគេដកឲ្យពូធ្វើកងចល័ត?

យុន ៖ កាលពីសម័យនឹងគេរំសាយកងទ័ពចេញ កងទ័ពម៉ាទាំងអស់គេដកទាំងអស់ គេឲ្យទៅនៅធ្វើស្រែនៅនឹងម៉ង ។

ធានី ៖ នៅធ្វើស្រែសុទ្ធ?

យុន ៖ បាទ!

ធានី ៖ ដឹងមូលហេតុអីបានគេឲ្យដកអីចឹងទេ?

យុន ៖ ខ្ញុំអត់ដឹង ។

ធានី ៖ ហើយអ្នកណាគេអ្នកឲ្យដក?

យុន ៖ មិនដឹងថាបញ្ជាពីអង្គការថ្នាក់លើមក ។

ធានី ៖ កាលពេលបែក៧៥ភ្លាមៗ ពេលនឹងមានប្រជាជនថ្មីជម្លៀសមកបាត់ដំបង?

យុន ៖ ប្រជាជនជម្លៀសចេញពីទីក្រុងមកនៅតាមវាល តាមភូមិនឹង ។

ធានី ៖ ពូដំបូងមានប្រមូលសម្ភារៈចូលក្នុងអីទេ?

យុន ៖ ខ្ញុំអត់ដែលមាន អត់មានចង់បានអីកាលពីសម័យនឹង ។

ធានី ៖ គេមានឲ្យយើងជាទ័ពដើរប្រមូលសម្ភារៈដូចជាតាមទីផ្សារ?

យុន ៖ អានឹងមានកងគេផ្សេង ។

ធានី ៖ មិនមែនពូ?

យុន ៖ បាទ!

ធានី ៖ ពូអត់ទេ?

យុន ៖ អត់ ។

ធានី ៖ ពូធ្វើស្រែ?

យុន ៖ ធ្វើស្រែជាមួយប្រជាជន មានកងការពារទីក្រុងគេផ្សេង ។

ធានី ៖ ខាងណាវិញ កងការពារទីក្រុង?

យុន ៖ ខ្ញុំមិនដឹងដែរ ប៉ុន្តែពួកខ្ញុំគេឲ្យនៅតាមថ្នាក់គោល ដូចថាដើរធ្វើការតាមភូមិប្រជាជន ហើយប្រជាជនធ្វើស្រែដកស្ទូងទៅជាមួយចូលរួមធ្វើ ។

ធានី ៖ មិនមែនចាំតែមានគេស្នើ?

យុន ៖ អត់មានទេ ។

ធានី ៖ ហើយដល់ពេលឆ្នាំ៧៦ លែងធ្វើទាហាន?

យុន ៖ អត់ ។

ធានី ៖ ធ្វើប្រជាជន?

យុន ៖ ធ្វើកងចល័ត ។

ធានី ៖ ធ្វើកងចល័តនៅណាវិញ?

យុន ៖ នៅវាលសាយសាម៉ន ។

ធានី ៖ ពូនៅនឹងធ្វើកងចល័ត ធ្វើការងារអីខ្លះ?

យុន ៖ លើកភ្លឺ ធ្វើស្រែចំការជាមួយគេ ដកស្ទូងជាមួយគេ ។

ធានី ៖ គេហៅកងចល័តអីគេ?

យុន ៖ ចល័តភូមិភាគ ។

ធានី ៖ ប្រចាំភូមិភាគពាយ័ព្យ?

យុន :	បាទ!

ធានី :	នៅតែថ្មគោលទេ?

យុន :	អត់ទេ អានឹងចេញពីថ្មគោល នៅសាយសាម័ន ។

ធានី :	នៅកន្លែងណា?

យុន :	នៅឯលិចដងស្ទឹងភ្នំតូច ។

ធានី :	ភ្នំតូចបន្ទាយមានជ័យនេះ?

យុន :	បាទ! ហ្នឹងហើយ ។

ធានី :	អានឹងគេហៅកងចល័តភូមិភាគ?

យុន :	ចល័តភូមិភាគ ។

ធានី :	តែពូទេ ឬមានអ្នកផ្សេងទៀតធ្វើកងចល័ត?

យុន :	ទាំងអស់គ្នា ទាំងទ័ពទាំងអស់ដែលរំសាយចេញពីកងចល័ត ។

ធានី :	ហើយពូនៅធ្វើប្រធានដដែល?

យុន :	អត់ទេ ខ្ញុំនៅកូនចៅគេ ។

ធានី :	កូនចៅអ្នកណាគេ?

យុន :	ខ្ញុំអត់ដឹង ដឹងគេមកពីណាណៃ ចល័តគេនៅនឹងមុន គេមើលនៅនឹង ។

ធានី :	ពូស្គាល់ឈ្មោះគាត់?

យុន :	ខ្ញុំភ្លេចឈ្មោះហើយ មិនដឹងឈ្មោះអី ។

ធានី :	ប្រធានចល័តភូមិភាគនឹង?

យុន :	បាទ!

ធានី :	គេណាគ្រប់គ្រងពីលើគាត់?

យុន :	ខ្ញុំអត់ដឹងទេ ខ្ញុំទៅនៅជាមួយគេបាន៣ខែ ដល់ពេលហើយគេហៅពួកខ្ញុំទៅរៀនសូត្រវិញ គេបំពាក់កាំភ្លើងឲ្យវិញ ។ គេប្រាប់ គេរៀនម៉ាថ្ងៃនឹងគេថា ឲ្យទៅវៃថៃ ពួកខ្ញុំប៉ុន្មាន១០០ នាក់ គេបញ្ជូនទៅភ្នំដងរែក រហូតដល់នឹងខ្ញុំដើរការពារនៅជើងភ្នំដងរែកនឹង ។ ខ្ញុំត្រូវរបួស ឆ្នាំ៧៧នឹង ខ្ញុំទៅនៅមន្ទីរពិការនឹងទៅសម្រាកនៅមន្ទីរពេទ្យបាត់ដំបង ។ នៅមន្ទីរពិការរហូត ដល់ឆ្នាំ៧៩ ដែលយួនចូលមកនឹង គេបញ្ជូនមកនឹង ។

ធានី :	ចុះឆ្នាំ៧៨នោះ?

យុន :	៧៨ ដែលខ្ញុំនិយាយថាចេញមកនៅនឹងទាំងអស់ ។

ធានី :	ចេញនៅណា?

យុន ៖ មកនៅអីនៅភ្លេចប្រាប់ភូមិ នៅថ្មពួក ។

ធានី ៖ ពូថាពិការនៅឆ្នាំ៧៧?

យុន ៖ ឆ្នាំ៧៧ ៧៨នឹង ។ ៧៧ខ្ញុំត្រូវរបួស ដល់ហើយខ្ញុំដេកនៅពេទ្យនៅបាត់ដំបង ឆ្នាំ៧៨ខ្ញុំនៅមន្ទីរពិការរហូត ។

ធានី ៖ ពូថាវ៉ៃនៅម៉ាឡៃ?

យុន ៖ អានឹងវ៉ៃថាចុងឆ្នាំ៧៧ ចូល៧៨ ។

ធានី ៖ ពូថានៅ៧៦កងចល័ត?

យុន ៖ កងចល័ត ។

ធានី ៖ ពូថានៅ៣ខែ គេឲ្យទៅរៀនសូត្រ?

យុន ៖ មករៀនសូត្រគេបំពាក់កាំភ្លើងឲ្យមក ។

ធានី ៖ ៧៦រៀនសូត្រនៅណា?

យុន ៖ រៀនសូត្រនៅបវេល ។

ធានី ៖ គេបង្រៀនថាម៉េចខ្លះទៅ?

យុន ៖ គេបង្រៀន គេឲ្យយើង គេបំពាក់កាំភ្លើងមកឲ្យតស៊ូ ដូចថាការពារព្រំដែន គេថាថៃយកទឹកដីយើង ។

ធានី ៖ អ្នកណាមកបង្រៀនពូ?

យុន ៖ មេកងទ័ពខ្ញុំ ។

ធានី ៖ ពូអីគេ?

យុន ៖ ណាំ ។

ធានី ៖ បង្រៀនប៉ុន្មាននាក់?

យុន ៖ គ្នា១០០នាក់ ។

ធានី ៖ រៀនសូត្របាន៣ខែ បានចាប់ផ្តើមទៅវ៉ៃ?

យុន ៖ រៀនម៉ាថ្ងៃ ។

ធានី ៖ រៀនឲ្យទៅវ៉ៃ?

យុន ៖ រៀនបំពាក់នយោបាយឲ្យយើងមានកម្លាំងតស៊ូ ឲ្យមានការឈឺចាប់ដើម្បីកុំឲ្យខ្មាំងយកទឹកដីយើង ។

ធានី ៖ ពូនៅ៧៦ធ្វើស្រែរហូត៣ខែចុងខែ?

យុន ៖ ចុងខែ៧ហើយ អឺ!ចុងឆ្នាំ៧៦ ។

ធានី ៖ ឆ្នាំ៧៧បានគេឲ្យទៅវៃដាមួយថៃ?

យុន ៖ បាទ!

ធានី ៖ ៧៧នឹងដឹបូងទៅភ្នំដងរែកសិន?

យុន ៖ ទៅដល់ដងរែកហើយឡប់មកនេះវិញ ។

ធានី ៖ មកណា?

យុន ៖ មកវៃដែលខ្ញុំថាឆ្នាំ៧៨ មកខាងម៉ាឡៃ ។

ធានី ៖ កាលពេលទៅដងរែកមានបានវៃដាមួយថៃទេ?

យុន ៖ អត់មានទេ ។

ធានី ៖ នៅការពារទឹកដី?

យុន ៖ បាទ!

ធានី ៖ ពូឡើងដល់លើភ្នំតែម្ដង?

យុន ៖ ខ្ញុំឡើងដល់ឡាក់២៦ ។

ធានី ៖ នៅណាឡាក់២៦?

យុន ៖ នៅលើភ្នំដងរែក ។

ធានី ៖ កាលនឹងពូងារជាអី?

យុន ៖ ខ្ញុំជាមេក្រុម ។

ធានី ៖ មេក្រុមម៉េចទៅ?

យុន ៖ មេក្រុមមាន៣នាក់ មានមេក្រុម អនុក្រុមមួយ ហើយនឹងមេពួកមួយ ។

ធានី ៖ ពូប្រធានមេក្រុម?

យុន ៖ បាទ!

ធានី ៖ មេក្រុមនឹងមានមនុស្សប៉ុន្មាននាក់?

យុន ៖ មាន១០នាក់ ។

ធានី ៖ អនុឈ្មោះអីគេ?

យុន ៖ ឈ្មោះ យាន ។

ធានី ៖ ស្រី ប្រុស?

យុន ៖ ប្រុស ។

ធានី ៖ ហើយមួយទៀតសមាជិក?

យុន ៖ សមាជិកមេពួក ។

ធានី ៖ ឈ្មោះអីគេ?

យុន ៖ ឈ្មោះ មុយ ។

ធានី ៖ ៣នាក់?

យុន ៖ ផ្សេងទៀត ។

ធានី ៖ ពូថាបានទៅភ្នំដងរែកហើយត្រឡប់មកភូមិវិញ?

យុន ៖ បាទ!

ធានី ៖ មកទាំងអស់គ្នាដែរ?

យុន ៖ មកទាំងអស់ ។

ធានី ៖ មកនៅភូមិណា កាលនឹងត្រឡប់មកបាត់ដំបង?

យុន ៖ អត់មានមកនៅម៉ាជួរដងស្ទឹងបវេល អានឹងចូលឆ្នាំ៧៨ហើយ ។

ធានី ៖ ត្រឡប់មកបវេលធ្វើអី?

យុន ៖ បវេលមកនៅបាន២ខែ ហើយឡប់ទៅដងរែកវិញ ។

ធានី ៖ មក២ខែនៅនឹងធ្វើអី?

យុន ៖ គេឲ្យមកធ្វើការនៅនឹង ។

ធានី ៖ ធ្វើការអីគេ?

យុន ៖ ដើរល្បាតតាមដងស្ទឹងនឹង ។

ធានី ៖ ល្បាតធ្វើអី?

យុន ៖ ល្បាតយាមកាម ការពារថាមានខ្មាំងចេញចូល ។

ធានី ៖ ហើយពូជួបអីខ្លះល្បាតនឹង?

យុន ៖ អត់មានស្អីផង ។

ធានី ៖ គេឲ្យល្បាតធ្វើអី?

យុន ៖ ចេះដើរទៅ ព្រោះទាហានមានការងារវាមានតែដើរធ្វើការយាមកាមប៉ុននឹងឯង ។

ធានី ៖ បន្ទាប់មកទៀតពូទៅដងស្ទឹងវិញ?

យុន ៖ បាទ!

ធានី ៖ ចុះពូថាទៅវៃខ្មែរសេរីនៅម៉ាឡៃ?

យុន ៖ ហ្នឹងមកវៃនឹងៗហើយឡប់ទៅដងរែកវិញ ។

ធានី ៖ នៅបវេលរយៈពេល២ខែនឹង ពូយាមល្បាតនៅតាមដងស្ទឹងការពារនឹងគឺ?

យុន : ការពារដេនស៊ីននឹងហើយ ដល់នេះគេឲ្យមកធ្វើការនៅម៉ាឡៃនឹង មកធ្វើការនឹងអត់មានខ្លាំងណាចេញចូល វាស្ងប់ហើយគេឡប់ទៅដេនវែកវិញ ។

ធានី : ការធ្វើការនៅម៉ាឡៃធ្វើការនៅកន្លែងណា?

យុន : ដើរធ្វើការតាមព្រៃ ។

ធានី : ព្រៃកន្លែង ម៉េចបានពូដឹងព្រៃនឹងហៅម៉ាឡៃ?

យុន : ចុះបើមេបញ្ជាការគេប្រាប់ថាអីចឹង ។

ធានី : អ្នកណាគេ មេបញ្ជាការនឹង?

យុន : ណាំនឹង ។

ធានី : កាលនឹងពូដើរត្រឹមប៉ុន្មាន បានដឹងថាកន្លែងនឹងម៉ាឡៃ?

យុន : ខ្ញុំមកដល់ព្រំដែននឹងម៉ង ។

ធានី : មកដល់ព្រំដែនយើងនេះ?

យុន : បាទ! មកតាមព្រៃរុកក្នុងព្រៃមកដេកផ្លូវពាយប់ ។

ធានី : ដើរតាមផ្លូវណាពីចាំទេ?

យុន : កាត់ព្រៃមកម៉ង ។

ធានី : ចាំទេ ចេញពីបវេលមកដល់កន្លែងណា?

យុន : ចេញពីបវេលនឹងមកព្រៃមករហូត ។

ធានី : ព្រៃរហូតដល់ព្រំដែននេះ?

យុន : បាទ! រហូតដល់ខែ៨ ឆ្នាំ៧៨នឹង ទៅភ្នំដេនវែកវិញ ខ្ញុំដើរធ្វើការ ខ្ញុំត្រូវរបួស ដេកពេទ្យនឹងនៅមន្ទីរពិការរហូតដល់ឆ្នាំ៧៩នឹង ។

ធានី : ពូដឹងថាកាលនឹងម៉ាឡៃស្ថិតនៅតំបន់ណា?

យុន : ម៉ាឡៃ ខ្ញុំអត់ដឹងដែរ មិនដឹងនៅតំបន់ណា តំបន់ប៉ុន្មានផង ។

ធានី : ពូដឹងថាស្រុកថ្មគោល?

យុន : ស្រុកថ្មគោល អានឹងតំបន់៣ ។

ធានី : ដល់ពេលស្រុកបវេល?

យុន : ស្រុកបវេល កាលនឹងខ្ញុំមិនសូវចាប់អារម្មណ៍ផង គេប្រាប់ត្រឹមប៉ុន្មាន ចេះត្រឹមនឹងដឹងត្រឹមនឹង ។

ធានី : កាលនឹងគេប្រាប់ពូថាម៉េច បានពូមកដល់ម៉ាឡៃ គេប្រាប់ថាមកម៉ាឡៃ?

យុន : បាទ! អានឹងដែលពេលឆ្នាំ៧៩ ។

ធានី ៖ មុននឹងដែលពូថាទៅរ៉ៃខ្មែរសេរី?

យុន ៖ គេប្រាប់ថាឲ្យដើរធ្វើការ មកព្រំដែនមើលៗផ្លូវខ្មាំងមានខ្មាំងចេញចូល ។

ធានី ៖ គេមានប្រាប់ថាឲ្យមកម៉ាឡៃទេ?

យុន ៖ គេប្រាប់ ។

ធានី ៖ ម៉ាឡៃនឹងមិនមែនមានឈ្មោះពីឥឡូវ?

យុន ៖ អត់ទេ យូរហើយ តាំងពីសង្គម ។

ធានី ៖ ពូដឹងធ្លាប់ឮឈ្មោះពីមុនមកទេ?

យុន ៖ កាលពីដើមមកខ្ញុំអត់ដឹង ដល់ពេលខ្ញុំទៅនៅគេនិយាយប្រាប់ទៅបានគេដឹង ។

ធានី ៖ គេនិយាយប្រាប់ថាម៉េច?

យុន ៖ គេប្រាប់ថា ព្រៃនឹងព្រៃភ្នំតំបន់ម៉ាឡៃម៉ង ។

ធានី ៖ អ្នកណាអ្នកនិយាយប្រាប់ពូ?

យុន ៖ អ្នកដែលគេស្គាល់គ្នាប្រជាជន ដែលគាត់នៅជិតៗ ។

ធានី ៖ ជិតៗខាងណា?

យុន ៖ ខាងភូមិសាយសាម៉ន ដែលខ្ញុំនិយាយនឹង ។

ធានី ៖ ភូមិសាយសាម៉ននៅក្នុងឃុំអី?

យុន ៖ អត់ដឹង ខ្ញុំមិនដឹង ។

ធានី ៖ ចុះឥឡូវវានៅភូមិឃុំអី?

យុន ៖ អត់ដឹង ។

ធានី ៖ នៅក្បែរយើង?

យុន ៖ ឆ្ងាយ ជិតទៅនោះវិញ ជិតទៅបវេលនោះវិញ ។

ធានី ៖ គេហៅកន្លែងនឹងតំបន់ម៉ាឡៃ អត់ដឹងថាកកើតពេលណាអត់ដឹង?

យុន ៖ អត់ដឹង ។

ធានី ៖ ពូស្គាល់ទំនប់ម៉ាក់ហឺនទេ?

យុន ៖ ម៉ាក់ហឺនខ្ញុំមិនស្គាល់ច្បាស់ផង ។

ធានី ៖ ដែលធ្លាប់ឮថាមានទំនប់នឹងនៅម៉ាឡៃកាលពីមុន?

យុន ៖ អត់ដែលដឹង ។

ធានី ៖ កាលពេលដើរមកនឹង អត់ដឹងថានៅនឹងមានទំនប់?

យុន ៖ ឡានគេជូនមក ។

ធានី ៖ ជូនមកត្រឹមណា?

យុន ៖ ឡានគេជូនមកដល់ត្រឹមម៉ាឡៃនឹង ។

ធានី ៖ ក្រែងសុទ្ធតែព្រៃម៉េចមានឡានដល់?

យុន ៖ អានេះមានផ្លូវគេពីកូនដំរីនឹងមក ផ្លូវពីសង្កម ផ្លូវជាតិគេទៅប៉ៃលិន ។

ធានី ៖ មានផ្លូវពីនឹងទៅដល់ប៉ៃលិនដែរ ពីសង្កម?

យុន ៖ បាទ! ហ្នឹងហើយ ឡានគេយកជញ្ជូនគ្រួសារទ័ព ហើយនឹងអ្នកពិការមកទុកនៅនឹង ។

ធានី ៖ គេយកមកទុកនៅនឹង?

យុន ៖ បាទ!

ធានី ៖ កាលពេលមកដំបូងមានផ្ទះមានអីដូចឥឡូវ?

យុន ៖ អត់មានទេ ។

ធានី ៖ ហើយគេមកនៅម៉េចទៅ បើសុទ្ធតែ?

យុន ៖ មកធ្វើដំបូល កាប់ឈើធ្វើដំបូលប្រក់កៅស៊ូ ប្រក់អីទៅ ។

ធានី ៖ គ្រួសារទ័ព ហើយនឹងអ្នកពិការមកនៅនឹង?

យុន ៖ នៅនឹង ។

ធានី ៖ បានអីហូប?

យុន ៖ អង្ករគេបើកឲ្យហូប ។

ធានី ៖ មកដល់ស្រុកយើងទេ កាលពេលជូនប្រជាជនមក?

យុន ៖ អ្នកណាគេជូន?

ធានី ៖ ពូនិយាយមិញ?

យុន ៖ អានឹងមេបញ្ជាការទ័ពនឹង ដែលក្រសួងមន្ទីរគេនឹង គេប្រមូលប្រជាជន អ្នកពិការអីមក គេយកមកទុកនៅនឹង ហើយគេទៅវិញទៅ ។

ធានី ៖ អត់មានអ្នកណាគេការពារគាត់?

យុន ៖ អត់មានទេ អង្ករមានហូប គេដឹកអង្ករម្ហូបយកមកឲ្យហូបត្រឹមអីនឹង ។

ធានី ៖ ចុះពូដឹងថាអ្នកណាគេគ្រប់គ្រងម៉ាឡៃដំបូង?

យុន ៖ រឿងម៉ាឡៃដំបូងខ្ញុំអត់ដឹង ។

ធានី ៖ ពីសង្កមចាស់?

យុន ៖ អត់មាន មិនមានមនុស្សនៅផង មានតែទ័ព ។

ធានី ៖ ទ័ពខាងណា?

យុន ៖ កាលពីសង្គមមានទាហាន កាលនឹងទាហានលន់នល់ ។

ធានី ៖ ដែលពូថាមកវ៉ៃខ្មែរសេរីនឹង?

យុន ៖ ហ្នឹងហើយ ។

ធានី ៖ ទាហានលន់ នល់នៅម៉ាឡៃនឹង?

យុន ៖ នៅម៉ាឡៃ ។

ធានី ៖ ហើយគេបញ្ជូនពូឲ្យមកវ៉ៃនៅម៉ាឡៃ?

យុន ៖ បាទ!

ធានី ៖ ប៉ុន្តែអត់បានវ៉ៃទេ?

យុន ៖ អត់បាន ។

ធានី ៖ ហេតុអី?

យុន ៖ វាអត់មានឃើញផង ។

ធានី ៖ ម៉េចគេថាមាន?

យុន ៖ គេថាមានចេះមកតាមគេៗបញ្ជូនមកម៉ាថ្ងៃ២ថ្ងៃអីទៅវិញ ។

ធានី ៖ ហើយពូមើលទៅម៉េចដែរ ពេលមកដំបូងមកដល់ម៉ាឡៃ?

យុន ៖ មកដល់ដំបូងមានម៉េចផង ឃើញតែព្រៃឃើញអី មិនមានឃើញអីប្រជាជនណាផង ។

ធានី ៖ ព្រៃយ៉ាងម៉េច?

យុន ៖ ព្រៃដើមឈើធំៗ ។

ធានី ៖ ងងឹតមេឃទេ?

យុន ៖ បាទ! យប់ឡើងក្នុងព្រៃនឹង តែម៉ោង៥អីនឹងងងឹតមើលគ្នា វាមានផ្សិតភ្លឺៗដូចភ្លើងៗពិល
គេហៅថាផ្សិតភ្លឺ ។

ធានី ៖ ផ្សិតម៉េច?

យុន ៖ វាដុះតាមមែកឈើ ស្លឹកឈើ មើលទៅភ្លឺ ។

ធានី ៖ ស្អាត?

យុន ៖ ភ្លឺដូចឃើញកាន់ទូរស័ព្ទ ។

ធានី ៖ មានតែផ្សិតនឹងម្យ៉ាង មានអីប្លែកជាងនឹង?

យុន ៖ ដង្កូវក៏ភ្លឺ ដង្កូវយប់ឡើងវាកើមឃើញភ្លើងវាភ្លឺដូចអំពិលអំពែក ។

ធានី ៖ មានអំពិកអំពែក?

យុន ៖ អំពិលអំពែកមានដែរមួយៗ មើលទៅក្នុងព្រៃស្លឹកឈើភ្លឺ ប៉ះណាភ្លឺម៉្លុំទៅ រែកទៅស្លឹកឈើ វាដូចមានជាតិបារត ។

ធានី ៖ ព្រោះពូថានៅ២ខែ ពូអាចជួយរៀបរាប់?

យុន ៖ មិនដឹងរៀបរាប់ពីស្អីផង ។

ធានី ៖ ចុះពេលពូមកដល់ដំបូងពូមានអារម្មណ៍ម៉េចដែរ?

យុន ៖ ធម្មតា ចុះមនុស្សវាមកគ្នាច្រើន យើងមិននឹកភ័យខ្លាចអីអាងមានគ្នានៅហើយ ។

ធានី ៖ មានអារម្មណ៍ម៉េចដែរ មើលទៅឃើញប្លែកខុសពីអ្នកស្រុកយើងម៉េច?

យុន ៖ គ្រាន់យើងនៅក្នុងព្រៃវាអត់មានបានឃើញឡានម៉ូតូនឹងគេ អត់ឃើញមាន ។ ហើយយប់ឡើងនាំគ្នាចងអង្រឹងដេក ។

ធានី ៖ មានមូសមានអីទាំ?

យុន ៖ មូសមាន ប៉ុនមូសភាគច្រើនមានតែថ្ងៃ យប់អត់ទេ ។

ធានី ៖ មូសថ្ងៃមូសស្អីគេ ពូដឹងទេ?

យុន ៖ មិនដឹងមូសស្អីទេ មូសខ្លា មូសដែកគោល មូសស្អី បើថាយប់អីនឹងអត់មាន ដល់ថ្ងៃរះឡើងនឹងមូសសំបូរណាស់ គេថាមូសនឹងវារកស៊ីថ្ងៃ ហើយយប់វាដេក ។

ធានី ៖ មូសរូបរាងដូចមូសយើងឥឡូវ?

យុន ៖ បាទ! ដូចគ្នា ។

ធានី ៖ អត់មានធំតូច?

យុន ៖ មានធំតូចដូចគ្នា ។

ធានី ៖ មានមូសធំៗ?

យុន ៖ បាទ!

ធានី ៖ មានអ្នកណាគ្រុនចាញ់មានអី ដល់ពេលមានមូសច្រើន ។

យុន ៖ កាលនឹងអត់ទាន់ដឹង វាមិនទាន់ដឹងថាមានជម្ងឺគ្រុនចាញ់អីទេ ប៉ុនថាអ្នកណាគ្រុនគឺស្លាប់អីចឹងតែម្តង អត់មានថ្នាំព្យាបាល ។

ធានី ៖ គ្រុនគឺស្លាប់?

យុន ៖ បាទ! ញាក់ញ័ររហូតឆ្នាំ៧៩ ភាគច្រើនពួកអង្គការកាកបាទបរទេសគេមក អ្នកដែលគ្រុនគេចែកថ្នាំឲ្យទៅ បារាំងគេយកចិត្តទុកដាក់គេមើលថែអីចឹង ។

ធានី ៖ ដល់ពេលពូមក៧៨នឹងអត់មានថ្នាំអីទាំងអស់?

យុន ៖ អត់មានទេ ។

ធានី ៖ អ្នកដែលមកពូថាអ្នកពិការ ហើយនឹងគ្រួសារកងទ័ពមកដែរ?

យុន ៖ បាទ! រហូតដល់ឆ្នាំ៧៩នឹង មានតែថ្នាំពេទ្យគេតាមមកនឹង គាត់ថាគ្រុនញាក់គេចាក់ថ្នាំទឹកខៀវៗតែប៉ុននឹង ។

ធានី ៖ ចាក់ហើយជា?

យុន ៖ ចាក់ទៅជា ភាគច្រើន ។

ធានី ៖ ពូបានឈឺនឹងគេ?

យុន ៖ ខ្ញុំគ្រុននឹងគេប៉ុន្មានម៉ាខែ ។

ធានី ៖ គ្រុននឹងម៉ាខែ ចាក់ថ្នាំនឹងទៅ?

យុន ៖ ចាក់ថ្នាំ ហើយលេបថ្នាំខ្លះទៅជា ។

ធានី ៖ លេបថ្នាំអីទៅ?

យុន ៖ មិនដឹងថាថ្នាំអី គេថាថ្នាំគ្រុនចាញ់ ។

ធានី ៖ ពូអត់ដឹងអានឹងហៅគ្រុនចាញ់ម៉េចទេ?

យុន ៖ អត់ទេ ។

ធានី ៖ គេឲ្យលេបថ្នាំ?

យុន ៖ លេប ។

ធានី ៖ លេបរាល់ថ្ងៃ?

យុន ៖ លេបជាប់រាល់ថ្ងៃព្រឹកល្ងាច ។

ធានី ៖ ពូមិញថាមានលើស្លឹកឈើមានពន្លឺភ្លឺៗ ដង្កូវភ្លឺៗ ផ្សិតក៏ភ្លឺ មានអីទៀតភ្លឺទៀត?

យុន ៖ មានអី មានតែអំពិលអំពែក ។

ធានី ៖ អត់មានសត្វអីផ្សេងៗភ្លឺ?

យុន ៖ អត់ ។

ធានី ៖ ចុះនៅនឹងសំបូរសត្វ?

យុន ៖ សត្វសំបូរ ។

ធានី ៖ ពូនៅអីចឹងម៉េចទៅ?

យុន ៖ វាអត់ហ៊ានមកជិតយើង ដូចជាខ្លា ដំរី វារត់គេចអស់ ។

ធានី ៖ មានដំរីទៀត?

យុន ៖ មាន ប៉ុន្តែមិនដែលឃើញទេ ថ្ងៃឡើងដើរឃើញដានឃើញតែអី ។

ធានី ៖ អត់ដែលឃើញវាមកដល់?

យុន ៖ បាទ! បើខ្វាអីវាតែស្រែដែរ យប់ឡើងមួងម្កាល ។

ធានី ៖ ស្រែម៉េចទៅ?

យុន ៖ ខ្ញុំពិបាកធ្វើតាមណាស់ ខ្វាខ្ញុំមិនចេះធ្វើ ។

ធានី ៖ ម៉េចបានដឹងថាអានឹងខ្វា បើយើងមិនបានឃើញផង?

យុន ៖ ចាស់ៗគេប្រាប់ ។

ធានី ៖ នៅបាន២ខែត្រឡប់ទៅដងរែកវិញ?

យុន ៖ បាទ!

ធានី ៖ ទៅដងរែកពូថាពិការដេកពេទ្យនោះ?

យុន ៖ ពិការដេកពេទ្យខ្ញុំដើរជាន់មីន ។

ធានី ៖ នៅដងរែក?

យុន ៖ បាទ!

ធានី ៖ ជាន់មីនដែរ តែអត់ខូចជើងទេ?

យុន ៖ បាទ! គ្រាន់ពិការបែកឆ្អឹង ហើយត្រូវភ្នែក ។

ធានី ៖ ត្រូវភ្នែកតាំងពីឆ្នាំ៧៨មក?

យុន ៖ បាទ!

ធានី ៖ ជាន់មីនខាងណាគេដាក់?

យុន ៖ មីនពួកគេអ្នកនៅតាមព្រំដែននឹង ពួកទ័ពនឹង ។

ធានី ៖ បែកជើងឆ្វេង ឬជើងស្តាំ?

យុន ៖ ជើងស្តាំ អាជើងដាច់នេះ ។

ធានី ៖ អាចដើរបាន?

យុន ៖ ដើរបាន រហូតមកដល់ឆ្នាំ៩២បានខ្ញុំជាន់មីនម៉ាសារទៀតដាច់ ។

ធានី ៖ បន្ទាប់មកទៀតឆ្នាំ៧៩ វៀតណាមវ៉ៃចូលភ្នំពេញ ពូនៅណា?

យុន ៖ ៧៩ហ្នឹងឯង ដែលយួនមកដល់ស្វាយនឹង ពួកខ្ញុំរត់មកដល់នេះ ។

ធានី ៖ មកដល់ម៉ាឡៃវិញ?

យុន ៖ បាទ!

ធានី ៖ មុនដំបូងក្រែងពូនៅដងរែក?

យុន ៖ ដងរែក ចេញចូល២កន្លែងនឹង ខ្ញុំទៅមកៗ ។

ធានី ៖ ទៅមកធ្វើអី?

យុន :	កាលនៅមន្ទីរពិការនឹង  កាលនៅនេះ(ម៉ាឡៃ) វាអត់ទាន់ពិការទេ  ដល់ហើយទៅនោះ(ដងរែក) ពិការ ដល់ពេលពិការឃួនចូលគេដឹកយកមកទុកនៅនេះ(ម៉ាឡៃ) ។

ធានី :	មកទុកនៅម៉ាឡៃនឹង?

យុន :	បាទ!

ធានី :	ម៉ាឡៃកាលពេលពូមកដល់ដំបូងមានភូមិគេទេ?

យុន :	អត់មានទេ ។

ធានី :	តែមានផ្លូវចូល?

យុន :	បាទ! មកតាមផ្លូវម៉ក់ហឹន ។

ធានី :	ផ្លូវចាស់ហើយ?

យុន :	ផ្លូវពីសង្គមផ្លូវគេផ្លូវលំ ដូចផ្លូវយើងសព្វថ្ងៃ ។

ធានី :	ពេលពូចូលមកដល់ដំបូងពេលផ្លូវចូល មានភូមិឃុំគេដូចរាល់ថ្ងៃ?

យុន :	អត់មានទេ ។

ធានី :	ពីដំបូងកូនដំរីមក?

យុន :	អត់មានទេ ។

ធានី :	នៅម៉ក់ហឹនក៏អត់មានផ្ទះសម្បែងដែរ?

យុន :	អត់មានទេ ។

ធានី :	អត់ដែលឃើញ?

យុន :	អត់មានទេ ។

ធានី :	អត់ដែលឃើញដែរ?

យុន :	បាទ!

ធានី :	ទើបមកដល់ឥឡូវបានមាន?

យុន :	ឥឡូវនេះបានមានៗ អ្នកដែលមកនេះយកគ្នាប្តីប្រពន្ធបានកូនបានចៅ ។

ធានី :	ពូមកដល់នេះដំបូងអត់មានផ្ទះសូម្បីតែមួយ?

យុន :	អត់មាន ។

ធានី :	ឬក៏គេមកស្នាក់នៅបណ្តោះអាសន្នអីក៏អត់មានដែរ?

យុន :	អត់មាន ។

ធានី :	ពូមកដល់ក្នុងនេះបានចាប់ផ្តើមកសាងផ្ទះកសាងស្អី?

យុន :	បាទ!

ធានី ៖ កាលនឹងមានផ្ទះដែរ?

យុន ៖ អត់មានទេ យើងនៅធ្វើផ្ទះខ្លួនយើង។

ធានី ៖ ផ្ទះប្រក់តង់?

យុន ៖ ប្រក់ស្បូវ ច្រូតស្បូវប្រក់ទៅ។

ធានី ៖ ដល់ពេល៧៩បែកពួរត់ពីភ្នំដងរែកមកទៅស្វាយ?

យុន ៖ មកៗនឹងម៉ង មកដល់ម៉ាឡៃនឹង។

ធានី ៖ កាលនឹងម៉េចអ្នកណាគេឲ្យប្រជាជនមកនេះ តាណាំនឹង ឬ?

យុន ៖ ផ្សេងទៀត។

ធានី ៖ អ្នកណាគេ?

យុន ៖ ឈ្មោះ យាន ប្រធានមន្ទីរខាងមន្ទីរកងទ័ព។

ធានី ៖ កងទ័ពខាងណា?

យុន ៖ ទ័ពខាងថ្មពួក។

ធានី ៖ ម៉េចបានគាត់ស្គាល់ម៉ាឡៃ?

យុន ៖ ចុះបើគេប្រកាសប្រាប់ថាគ្រួសារយោធា ហើយអ្នកពិការអីយួនចូលមកគេថាឲ្យនាំជញ្ជូនជម្លៀសឲ្យមកនៅម៉ាឡៃ។

ធានី ៖ ដល់ពេលមុននឹងពួចូលមកម្តងហើយ?

យុន ៖ បាទ!

ធានី ៖ តែមិនមែនពួទេអ្នកផ្សេង?

យុន ៖ បាទ!

ធានី ៖ ពេលពួមកដល់នឹងឃើញមានគេនៅហើយ?

យុន ៖ ដែលពេលយួនចូលមក វៀតណាមចូលមក ដែលគេបញ្ជូនចូលមកគ្មានអ្នកមកទេ មានតែអ្នកទើបមកថ្មីទាំងអស់គ្នា រាប់រយរាប់ពាន់។

ធានី ៖ ចុះអ្នកមុន?

យុន ៖ អ្នកមុនកាលនឹងមកនៅអីចឹង ឡប់ទៅវិញ។

ធានី ៖ ឡប់ទៅវិញ ឡប់ទៅទាំងអស់គ្នា?

យុន ៖ បាទ!

ធានី ៖ ស្មានតែពួមកហើយទុកអ្នកនឹង ហើយពួទៅវិញ?

យុន ៖ អត់ទេ ចេញចូលទាំងអស់ ។ ពេលណាសភាពការណ៍ស្រួលគេទៅវិញ ដល់ពេលសំខាន់ ដែលចុងក្រោយបំផុតនឹងឆ្នាំ៧៩នឹង មកនៅរហូត ។

ធានី ៖ ពូមកនៅនេះ មកនៅណា?

យុន ៖ ខ្ញុំមកនៅនឹង ។

ធានី ៖ មកនៅផ្ទះពូ?

យុន ៖ ព្រៃ ។

ធានី ៖ ស្ថានមើលឥឡូវក្លាយជាអី?

យុន ៖ ឥឡូវភូមិគេពេញអស់ ។

ធានី ៖ ភូមិអីគេ?

យុន ៖ នៅភូមិនឹងម៉ង ភូមិកណ្ដាល ។

ធានី ៖ តែនៅខាងនោះ?

យុន ៖ បាទ! នៅខាងនោះ ។

ធានី ៖ ពូយ៉ាននឹង អ្នកដឹកនាំពូដែលជាកងទ័ព និងអ្នកគ្រួសារកងទ័ពមកនៅនេះ?

យុន ៖ នៅហ្នឹង ។

ធានី ៖ អត់មានប្រជាជនទេ?

យុន ៖ អត់មានទេ មានតែគ្រួសារកងទ័ព ហើយនឹងអ្នកពិការ ។

ធានី ៖ ហេតុអីបានគេរត់មកនៅកន្លែងនឹង ពូស្គាល់ ឬអ្នកផ្សេងស្គាល់?

យុន ៖ ទេ! មេៗគេអ្នក ។

ធានី ៖ យ៉ាននឹងស្គាល់?

យុន ៖ គេថាខ្មែរយើងវៀតណាមចូលមក យើងគ្មានទៅណា យើងមានទៅតំបន់ព្រៃភ្នំម៉ាឡៃ ដើម្បីជាកន្លែងព្រៃធំ កន្លែងតស៊ូរបស់គេ ។

ធានី ៖ នៅដងរែកមិនព្រៃធំដែរ ម៉េចបានគេមិនទៅនៅខាងនឹង?

យុន ៖ គេអត់នៅ កងទ័ពគេចេញមកនេះទាំងអស់ ។

ធានី ៖ កាលដំបូងដងរែកអត់មានអ្នកណាគេនៅទេ?

យុន ៖ អត់មានទេ ទ័ពតាំងពីសៀមរាបអីមកខាងនេះទាំងអស់ ។

ធានី ៖ ខាងណាអ្នកគ្រប់គ្រងសៀមរាប មានដឹងទេ?

យុន ៖ អត់ដឹង និយាយទៅកន្លែងនេះកន្លែងរួមមិនថាពួកណាទេ តាំងពីភ្នំពេញ ក្រចេះ ប្រមូលគ្នា មកនឹងទាំងអស់ មកឡាន...ឆ្នាំ៧៩ ។

ធានី : មានឡានគេចូលដល់នឹងទៀត?

យុន : ឡានដែលគេនៅ គេចេញមកគេដឹកកម្លាំងគេមកនឹង ។

ធានី : គេមានឡានជិះមកដល់នឹងដែរ?

យុន : បាទ!

ធានី : មិនចាំបាច់ដើរ?

យុន : អត់មានដើរទេ ។

ធានី : ជិះឡានដល់?

យុន : បាទ!

ធានី : កាលនឹងពូស្គាល់ដែរ ឬមួយអ្នកផ្សេងគេស្គាល់ដែរ?

យុន : ខ្ញុំអត់ស្គាល់ទេ គេយកមក គេនិយាយចេះនិយាយតាមគេ ស្គាល់តាមគេ ។

ធានី : ម៉េចដែរពូមកដល់លើកទី២?

យុន : លើកទី២មានម៉េច ព្រៃនៅដូចពីដើមនឹងឯង ព្រៃណែនព្រៃឬស្សីព្រៃឈើពេញណែន ។

ធានី : មានមីន?

យុន : អត់មានមីនទេ មីនម៉ាដួរអស់នេះមាននៅឆ្នាំ៨០ បានវៀតណាមមកនឹងបានមានមីន ។

ធានី : វៀតណាមអ្នកដាក់មីននឹង?

យុន : ពួកទ័ពខ្មែរក្រហមផង ហើយ ។

ធានី : ពួកខ្មែរក្រហមដាក់មុន ឬវៀតណាមដាក់មុន?

យុន : វៀតណាម ។

ធានី : វៀតណាមដាក់មុន?

យុន : បាទ! ដាក់ការពារបន្ទាយគេនឹងមិនឲ្យខ្មែរក្រហមចូលវ៉ៃ ។

ធានី : ចុះកាលនឹងវៀតណាមដាក់មីនកន្លែងណាខ្លះ បានការពារបន្ទាយមកដល់កន្លែងយើងដែរ?

យុន : បន្ទាយវានៅនោះ បន្ទាយវាតូចៗដែរ ។

ធានី : បន្ទាយវាតូចៗនៅជុំវិញយើងនឹង?

យុន : បាទ! ហើយខ្មែរយើងអ្នកនៅនេះនឹង ភៀសខ្លួនទៅនៅដីថៃទាំងអស់ ។

ធានី : ពូ៧៩មកដល់នេះ ហើយនៅឆ្នាំ៧២ ប្រឡូ?

យុន : ឆ្នាំ៨២ ។

ធានី : កាលពេល៨២ពូរៀបគ្រួសារ វៀតណាមចូលដល់?

យុន : ចូលដល់ បាទ!ចូលដល់នឹងហើយពួកអ្នកដែលនៅនេះចូលដីថៃទាំងអស់ ។

ធានី :	៨២ ឬ៨៥?

យុន :	៨២រហូតដល់៨៥ ឆ្នាំ៨៩បានឡប់មកនេះវិញ ។

ធានី :	តាំងពី៨០មកវៀតណាមចូលដល់នេះហើយ?

យុន :	បាទ!

ធានី :	ហើយគេចាប់ផ្ដើមវ៉ៃចុះឡើងដេញទៅដេញមកជាមួយខ្មែរក្រហម?

យុន :	ដេញទៅមក ដល់ពេលនេះហើយបានវៀតណាមវ៉ៃសំរុកខ្លាំងមក ពួកខ្ញុំចូលទៅដីថៃទាំងអស់គ្នា ។

ធានី :	កាលដំបូងអត់ចូលទៅដីថៃទាំងអស់ទេ?

យុន :	អត់ទេ នៅនឹង ។

ធានី :	នៅរប៉េះរប៉ោះៗនៅនេះ?

យុន :	បាទ!

ធានី :	ចុះមានអ្នកខ្លះរត់ទៅជំរំថៃទេ?

យុន :	គ្មានជំរំផង មានជំរំខ្មែរនៅដីថៃ ។

ធានី :	ជំរំម៉េច គេហៅជំរំអី?

យុន :	ជំរំតាឌុំក ។

ធានី :	តាឌុំកនៅកន្លែងណា នៅសំពៅលូន?

យុន :	ហ្នឹងហើយសំពៅលូន ។

ធានី :	នៅសំពៅលូនកន្លែងជំរំតាឌុំក?

យុន :	តាឌុំក ។

ធានី :	តែជំរំខ្មែរនៅលើដីថៃ?

យុន :	ហ្នឹងហើយជំរំនឹងជំរំខ្មែរនឹងជំរំតាឌុំក ។

ធានី :	យើងរត់ទៅនឹង?

យុន :	ហ្នឹងហើយប្រមូលគ្នាទៅនឹងទាំងអស់រាប់ពាន់រាប់ម៉ឺន ។

ធានី :	អានឹងនៅពេលវៀតណាម ដេញមកដល់ព្រំដែន?

យុន :	មកដល់ព្រំដែននឹង ។

ធានី :	វៀតណាមចូលតាំង៨០ គេដាក់មីនតៗរហូត?

យុន :	បាទ!

ធានី :	ហើយយើងដឹងកន្លែងមានមីនដាក់ការពារចុះឡើងៗ?

យុន ៖ បាទ!

ធានី ៖ រហូតដល់៨៥ បានរត់ទៅដីថៃទាំងអស់?

យុន ៖ បាទ!

ធានី ៖ បានពូនៅជំរំតាផ៊ុកដដែល ឬជំរំអីផ្សេង?

យុន ៖ បាទ! អត់មាន ។

ធានី ៖ មិនមែនជំរំ៨៥?

យុន ៖ ៨៥នឹងអានឹងឆ្នាំវាចូល ឆ្នាំដែលទៅនឹងឆ្នាំ៨៥ ។

ធានី ៖ ចុះពូថាជំរំតាផ៊ុកនោះ?

យុន ៖ ហ្នឹងហើយឈ្មោះតាផ៊ុក ឈ្មោះវានៅនឹងម៉ង ។

ធានី ៖ ជំរំតាផ៊ុក ប៉ុន្តែនៅឆ្នាំ៨៥ បានរត់ទៅទាំងអស់?

យុន ៖ បាទ! ឆ្នាំ៨៤នឹង ដល់ពេលអ្នកដែលគេធ្វើទ័ពគេមកនៅ៨៥ គេដាក់ឈ្មោះ៨៥ ។ ប្រជាជននៅតាផ៊ុកទាំងអស់ ។

ធានី ៖ ជំរំមាន២?

យុន ៖ បាទ!

ធានី ៖ ប្រជាជននៅជំរំតាផ៊ុក ដល់ពេល?

យុន ៖ ទ័ពដែលគេរត់ចេញពីនឹងទៅគេរត់ទៅនៅភូមិនឹងមួយ គេដាក់ឈ្មោះថាភូមិ៨៥ ជំរំ៨៥ អានឹងខាងគ្រួសារទ័ព ។

ធានី ៖ ពូរត់ទៅនឹងដែរ?

យុន ៖ ខ្ញុំនៅតាផ៊ុក ។

ធានី ៖ ក្រែងពូទ័ព?

យុន ៖ ចុះខ្ញុំពិការហើយ ។

ធានី ៖ ពិការនឹងធ្វើអីបានធម្មតា លែងធ្វើទាហានហើយ?

យុន ៖ ឈប់ធ្វើ ។

ធានី ៖ ក្រោពីពេលពូនៅដងរែងនឹងក៏ពិការដែរ ប៉ុន្តែគេដឹកមកធម្មតា?

យុន ៖ បាទ! គេដឹកមក ។

ធានី ៖ នៅឆ្នាំប៉ុន្មានដែលពូទៅជំរំតាផ៊ុក?

យុន ៖ ឆ្នាំ៨៤ ទៅខែ៨ ចូលដល់ឆ្នាំ៨៥បណ្តោយ ។

ធានី ៖ ពូថា៨២រៀបគ្រួសារ?

យុន :	បាទ!

ធានី :	រៀបនៅណា?

យុន :	រៀបនៅនេះ ។

ធានី :	គ្រួសារនៅម៉ាខ្សែនឹង?

យុន :	បាទ!

ធានី :	ដូចថាមានគេធ្វើពិធីម៉េចខ្លះទៅ?

យុន :	គ្មានផង រៀបការដូចយើងចូលស្ដីដណ្ដឹងម៉ែឪយើងពីដើម គាត់ថាអ្នកណាស្រឡាញ់អ្នកណា ដូចមិត្តក ស្រឡាញ់មិត្តខ ចូលប្រាប់កន្លែងប្រធានគេនឹង ស្នើដល់ប្រធានគេ ។

ធានី :	ពូជួយរៀបរាប់បានទេ ស្រឡាញ់អ្នកណាគេ ទៅប្រាប់អ្នកណាគេ ហើយគេថាម៉េច?

យុន :	ប្រាប់មេយើង ។

ធានី :	មេណា ឈ្មោះអីគេ?

យុន :	ឈ្មោះបង សាម៉ននៅសព្វថ្ងៃនឹង ។

ធានី :	គាត់ធ្វើអីគេ កាលសម័យនឹង?

យុន :	កាលសម័យនឹងប្រធានកងឈ្លប ។

ធានី :	ឈ្លបអីគេ?

យុន :	ឈ្លបការពារ ។

ធានី :	កងឈ្លបនឹងមានមនុស្សប៉ុន្មាននាក់កូនចៅគាត់?

យុន :	គ្នា១០០នាក់ ។

ធានី :	ពូនៅក្នុងកងនឹងដែរ ព្រោះពូពិការជើងនឹង?

យុន :	បាទ! នៅនឹង គាត់អ្នកគ្រប់គ្រង ។

ធានី :	សាម៉ននឹង គាត់អ្នកស្រុកណាមកពីណា?

យុន :	ខ្ញុំអត់ដឹង ។

ធានី :	ដល់ពេលពូស្នើទៅសាម៉ននឹងចង់បានអ្នកណាគេ?

យុន :	គ្រួសារខ្ញុំ ព្រាប រឿន ។

ធានី :	ស្នើទៅ?

យុន :	ស្នើទៅប្រធានគេ ។

ធានី :	គាត់នឹងអ្នកធ្វើអីគេ?

យុន :	គាត់នឹងធ្វើពេទ្យ ។

ធានី ៖ ប្រធានពេទ្យធ្វើអី?

យុន ៖ ឈ្មោះ យួន ។

ធានី ៖ អីគេយួន?

យុន ៖ អត់ដឹងត្រកូលគាត់ ។

ធានី ៖ រាល់ថ្ងៃកូនគាត់ធ្វើពេទ្យ?

យុន ៖ អត់មានធ្វើនៅនឹងផង ។

ធានី ៖ ស្នើហើយ?

យុន ៖ ដល់នេះខ្ញុំប្រាប់ប្រធានខ្ញុំទៅសួរស្នើឲ្យទៅ ដល់ហើយហៅមករៀបការឲ្យទៅ ។

ធានី ៖ រៀបការម៉េចទៅ?

យុន ៖ គ្រាន់អត់មានភ្លេងមានអី ការ ។

ធានី ៖ ការនឹងគេធ្វើម៉េច ដូចសម័យខ្មែរក្រហម?

យុន ៖ អត់ទេ ដូចតែយើងឥឡូវនឹងដែរ ។

ធានី ៖ មានអាចារ្យមានអី?

យុន ៖ បាទ!

ធានី ៖ មកពីណាវិញ អាចារ្យ?

យុន ៖ ចុះចាស់ៗមកជាមួយ ។

ធានី ៖ គាត់និយាយថាម៉េចខ្លះ?

យុន ៖ គាត់និយាយតាមច្បាប់ប្រពៃណីខ្មែរពីដើមយើង គ្រាន់តែមិនភ្លេង ។

ធានី ៖ ពូចាំ?

យុន ៖ គាត់ស្លាប់អស់ហើយ ។

ធានី ៖ គាត់ឈ្មោះអីគេ?

យុន ៖ ឈ្មោះ ដួត ។

ធានី ៖ ស្រី ប្រុស?

យុន ៖ ប្រុស ។

ធានី ៖ ពេលនឹងពូមានឪពុកម្តាយនៅជាមួយ?

យុន ៖ អត់មាន ខ្ញុំមកតែម្នាក់ឯង ។

ធានី ៖ ចុះគាត់?

យុន ៖ មកម្នាក់ឯង គាត់មកពីឆ្ងាយណាស់ នៅតាកែវ ។

ធានី ៖ ស្រុកកំណើតគាត់នៅតាកែវ?

យុន ៖ បាទ!

ធានី ៖ នៅភូមិឃុំអី?

យុន ៖ នៅភូមិរន្ទះ ។

ធានី ៖ ឃុំអី?

យុន ៖ ស្អីគេទេ ដឹងថាស្រុកគីរីវង់ ។

ធានី ៖ អត់ចាំ ដឹងភូមិភ្នំរន្ទះ ស្រុកគីរីវង់ ខេត្តតាកែវ?

យុន ៖ បាទ!

ធានី ៖ បន្ទាប់មកទៀតម៉េច គាត់នៅជាមួយពូហើយ គាត់ធ្វើការងារអីទៀតអត់?

យុន ៖ នៅធ្វើពេទ្យរាល់ថ្ងៃ ។

ធានី ៖ ពេទ្យអីគេ?

យុន ៖ ពេទ្យកន្លែង ពេទ្យប្រជាជនធម្មតា ។

ធានី ៖ ពេទ្យជម្ងឺទូទៅ?

យុន ៖ បាទ!

ធានី ៖ សព្វថ្ងៃក៏គាត់នៅធ្វើដែរ?

យុន ៖ អឺ!

ធានី ៖ ដល់ពេលពូ?

យុន ៖ ខ្ញុំអត់មាន ។

ធានី ៖ កាលពេលគាត់ធ្វើពេទ្យៗនៅជំរំតាង៉ុកនឹង?

យុន ៖ កាលដែលរត់នឹងគាត់ឈប់ធ្វើហើយ ដល់ពេលមកឆ្នាំ២០០០នេះ ដល់ពេលយើងឡប់មកវិញ មកនៅលើដីនេះវិញ នៅឆ្នាំ៨៩ ៩២ ។

ធានី ៖ ៨៩មកហើយទៅវិញ?

យុន ៖ អត់ទៅវិញទេ ចុះឡប់យើងចូលមកទឹកដីខ្មែរយើងវិញ មិនមកឆ្នាំ៨៩រហូតដល់ឆ្នាំ៩២ខ្ញុំជាន់មីនដាច់ជើង មកដល់ឆ្នាំ២០០០នេះបានគេហៅគាត់(ប្រពន្ធ)ឲ្យធ្វើពេទ្យវិញ ។

ធានី ៖ ៨៩ម៉ាខ្សែ មកដល់មានមីនមានអីហើយ?

យុន ៖ តាមអស់នេះសុទ្ធតែមីន ផ្ទះរបស់ខ្ញុំសុទ្ធតែរាវធ្វើនៅ ។

ធានី ៖ ពូរាវខ្លួនឯង?

យុន ៖ បាទ!

ធានី ៖ ពូចេះភាវដែរ?

យុន ៖ ចេះភាវទៅ ។

ធានី ៖ អត់ខ្លាច?

យុន ៖ ចុះបើអត់មានដីនៅហើយ នៅភាវបានដីបន្តិចៗម្នាក់ៗបួន់ៗ ។

ធានី ៖ ផ្ទះពូ?

យុន ៖ បាទ!

ធានី ៖ ផ្ទះពូនឹងកាលពេលភាវដីបួនប្រហែលប៉ុន្មានម៉ែត្រ ធ្វើផ្ទះនៅ?

យុន ៖ ភាវ២០ម៉ែត្រ ៣០ម៉ែត្រ ភាវប៉ុន្មានដីខ្ញុំភាវម៉ាខែ បានដី២វ៉ែ ។

ធានី ៖ ២វ៉ែនឹង បើគិតជាគីឡូ ហិចតាប៉ុន្មាន?

យុន ៖ ២វ៉ែ ១វ៉ែមាន៤០ម៉ែត្របួនជ្រុង ។

ធានី ៖ ពូភាវខ្លួនឯង?

យុន ៖ បាទ!

ធានី ៖ បានអីភាវទៅ?

យុន ៖ ដៃយើងធម្មតា យកប៉ែលចូកទៅ ។

ធានី ៖ ភាគច្រើនមីនដែលពូភាវបាន មីនអីទៅ?

យុន ៖ ភាគច្រើនមីនអន្ទាក់យើង គេដាក់លើគោក អាមីនដាន់លើដីវាបានភាគតិចមីនក្តារ មីនវៀតណាម ។

ធានី ៖ នៅផ្ទះពូសុទ្ធតែមីនអន្ទាក់ទាំងអស់គាត់ច្រើន?

យុន ៖ បាទ!

ធានី ៖ មីនអីគេ?

យុន ៖ មីនក្តារ ។

ធានី ៖ ពេលដោះពេលអីធ្វើម៉េច?

យុន ៖ ចូកឃើញ យើងឆ្កើសយកមកលើ យើងមួលដោះម្ជុរចេញ ។

ធានី ៖ ចន្លោះពេលដែលពូរស់នៅឆ្នាំ៧៩ មកដល់នេះ តើមានការលំបាកម៉េច? ជួបហេតុការណ៍អីខ្លះដែលពូមើលទៅចិត្តពូនៅចាំអត់ភ្លេច?

យុន ៖ ខ្ញុំអត់ឃើញមានលំបាកអីផង ។

ធានី ៖ ពូនៅទ័ព?

យុន ៖ អត់ទេ នៅពិការប្រជាជនធម្មតា ។

ធានី ៖ ដល់ឆ្នាំ៨៤ ពូរត់ទៅជិរំម៉េចដែរ ពេលទៅដល់នឹងឃើញម៉េចខ្លះទិដ្ឋភាពវា?

យុន ៖ ដល់នឹងចូលទៅដីថៃទៅ ឡានគេមកដឹកទៅឡានថៃយកទៅដាក់ជិរំតាឡឹក ។

ធានី ៖ ម៉េចដែរការរស់នៅជិរំ?

យុន ៖ រស់នៅជិរំយើងរស់នៅការហូបចុក បារាំងគេគ្រប់គ្រងកាកបាទគេចែកអង្ករ គេចែកម្ហូបអីឲ្យ ។

ធានី ៖ កាកបាទនឹងខាងកាកបាទអីគេ ពូដឹង?

យុន ៖ គេហៅកាកបាទក្រហម ។

ធានី ៖ របស់បារាំង?

យុន ៖ បារាំង ចែកតាំងពីអង្ករ ត្រីខ ។

ធានី ៖ នៅជិរំពូដែលដើរទៅណា?

យុន ៖ ខ្ញុំមិនដែលដើរទៅណាផង ។

ធានី ៖ ដល់ពេលពូមកវិញម៉ាឡៃបានអីហូប បើថានៅជិរំគេចែកអង្ករ?

យុន ៖ មកអង្ករគេយកមកឲ្យហូប ។

ធានី ៖ គេយកមកឲ្យហូបដល់ផ្ទះ?

យុន ៖ បាទ!

ធានី ៖ អត់មានខ្វះខាតទេ?

យុន ៖ អត់មានខ្វះទេ ។

ធានី ៖ គ្រាន់ពូនៅរាវតិចៗ?

យុន ៖ បាទ! យើងរាវរហូតមកដល់ឆ្នាំ៩២នឹង ខ្ញុំទៅរាវធ្វើស្រែនៅក្រោយបានខ្ញុំដាន់មីនដាច់នឹងបានខ្ញុំធ្វើអីមិនកើតរហូត ។

ធានី ៖ មានគេជួយ?

យុន ៖ គេជួយជាថ្នាំ តាំងពីរបស់របរហូបចុក នំ ។

ធានី ៖ ទាំងអស់គ្នាមិនមែនតែពូ?

យុន ៖ ទូទៅម៉ង ។

ធានី ៖ ដល់ឆ្នាំប៉ុន្មានបានគេឈប់ជួយ?

យុន ៖ ដល់ឆ្នាំ៩០ប៉ុន្មាន ឆ្នាំ៩៤ យើងរកបានខ្លួនយើងរហូតដល់សមាហរណកម្មយើងផ្តាច់ខ្លួនចូលជាមួយរដ្ឋាភិបាល យើងធ្វើស្រែធ្វើចំការខ្លួនឯងបានចេះពង្រីកព្រៃកាប់ព្រៃធ្វើទៅរហូតមកទល់ឥឡូវនឹង ។

ធានី ៖ ពេលដែលពួកាប់ព្រៃ មានអ្នកណាគេប្រាប់ថាធ្វើចេះ ឬមួយយើងធ្វើខ្លួនឯង?

យុន ៖ ធ្វើខ្លួនឯង ។

ធានី ៖ អត់មានអ្នកណាប្រាប់ឲ្យកាប់ព្រៃ?

យុន ៖ អត់ទេ បើអីចឹងមានគំនិតខ្លួនឯងនាំគ្នាធ្វើទៅ ព្រោះគេប្រកាសថាយើងគ្មានស្អីមានតែដីនេះឯង នាំគ្នាធ្វើរកបានធ្វើ ។

ធានី ៖ អ្នកណាគេប្រកាស?

យុន ៖ ជាទូទៅ ដូចជាមេកងមេភូមិគេអីចឹង មេភូមិ ។

ធានី ៖ អ្នកណាគេ?

យុន ៖ មេភូមិគាត់ស្លាប់ហើយ ។

ធានី ៖ ឈ្មោះអី?

យុន ៖ ឈ្មោះ ផេន ។

ធានី ៖ មេភូមិអ្នកមកប្រាប់ប្រជាជនឲ្យរានព្រៃកាប់ព្រៃខ្លួនឯង?

យុន ៖ បាទ! ហ្នឹងហើយ យើងមានបង់ពន្ធបង់អីទៀត ព្រោះសម័យនឹងមិនមានអ្នកយកពន្ធដារអីហើយចេះនាំគ្នាធ្វើរហូតនាំគ្នាមានដីមានស្រែមានចំការ មកឥឡូវនឹង ។

ធានី ៖ ចង់សួរពូបកក្រោយបន្តិច នៅពេលមកដល់ម៉ាឡៃដំបូងឆ្នាំ៧៩ តើអ្នកណាគេអ្នកចងក្រងឲ្យមានការគ្រប់គ្រង?

យុន ៖ ខ្ញុំវាមិនចាប់អារម្មណ៍ចងចាំលើអ្នកគ្រប់គ្រង ។

ធានី ៖ ចុះពេលណាដឹងថាម៉ាឡៃនឹងអ្នកណាគេអ្នកគ្រប់គ្រង?

យុន ៖ អានឹងខ្ញុំដឹងតាមកាលដែលមកយកមក ដល់មកគ្នាច្រើន គេមកគេប្រកាសថាយើងនៅកន្លែងនឹង ។

ធានី ៖ អ្នកណាគេអ្នកគ្រប់គ្រង?

យុន ៖ អត់មានអ្នកណាអ្នកគ្រប់គ្រងទេ គ្រាន់គេមកប្រាប់ថាម្ចាស់ការខ្លួនឯងនៅកន្លែងនឹង ។

ធានី ៖ អ្នកណាគេអ្នកប្រកាសនឹង?

យុន ៖ មេគេយកមកកងទ័ពនឹង ។

ធានី ៖ ឈ្មោះអីគេ?

យុន ៖ ឈ្មោះណំ ។

ធានី ៖ ណំនឹងអ្នកប្រកាសទៀត?

យុន ៖ បាទ! គេមកប្រាប់ថា ពួកមិត្តឯងតាំងទ័ពគ្រួសារ អ្នកពិការអីមកនៅនឹង ឥឡូវរកស៊ីប្រកបអាជីវកម្មខ្លួនឯងទៅ ។

ធានី ៖ ចុះមានអ្នកណាគេលើមិត្តណាំនឹង?

យុន ៖ ខ្ញុំអត់ដឹង១គាត់នៅណាឥឡូវ ។

ធានី ៖ ដឹងថាអ្នកណាលើគាត់?

យុន ៖ អត់ដឹង ។

ធានី ៖ ហេតុអីបានគេជ្រើសរើសយកម៉ាឡៃ?

យុន ៖ ខ្ញុំអត់ដឹងដែរ ។

ធានី ៖ បន្ទាប់ពី៩៤ ធ្លាប់មានពុកេប្រមូលទ្រព្យសម្បត្តិឯកជនចូលរួមវិញមានទេ?

យុន ៖ កាលនឹងមានដែរតើ ។

ធានី ៖ មានឆ្នាំប៉ុន្មាន?

យុន ៖ អត់ចាំ ។

ធានី ៖ ៩៤ ៩៣ ៩២ ៩១?

យុន ៖ មិនដឹង៩៣មិននឹង មិនសូវដឹងដែរ ។

ធានី ៖ ៩៣នឹងគេប្រមូលម៉េច ពូនិយាយប្រាប់បន្តិច?

យុន ៖ ប៉ុនណានេះជាគម្រោងការណ៍គេ គេថាឲ្យប្រមូលជារបស់របរដូចជាមានកងមានរទេះគោ គឺថាឲ្យប្រមូលដាក់ជារួម ដល់ហើយប្រជាជនគេអត់ព្រម គេខំតស៊ូតាំងពីណាពីណែបានប៉ុននឹងមក ។ អានឹងចូលក្នុងការផ្ដាច់ការ ដូចជាកាលសម័យ៣ឆ្នាំ ។

ធានី ៖ គេនិយាយអីចឹង?

យុន ៖ បាទ! គេនិយាយអីចឹង ។

ធានី ៖ ពូគាំទ្រដែរ?

យុន ៖ បាទ! ដល់ហើយប្រជាជនទាំងអស់នៅនឹងវាប្រឆាំងនៅនឹង ដល់អីចឹងធ្វើអត់បាន ។

ធានី ៖ អ្នកណាគេអ្នកផ្ដើមគំនិត?

យុន ៖ កាលពីសម័យនឹង កាលនឹងមានតាម៉ុក ។

ធានី ៖ គាត់មកដល់នឹងដែរ?

យុន ៖ មកដល់នឹង ចុះគាត់មេទ័ព ដល់អីចឹងមកដល់កន្លែងនឹងឲ្យប្រជាជនធ្វើអីចឹង ប្រជាជនអត់ធ្វើតាម ។

ធានី ៖ មានតែតាម៉ុកម្នាក់ អត់មានអ្នកផ្សេងទៀត?

យុន :	អត់មាន ខ្ញុំអត់ដឹងដែរ ។

ធានី :	ចុះក្រៅពីតាម៉ុកដឹងមានអ្នកផ្សេង?

យុន :	អត់ដឹង

ធានី :	ម៉េចបានពូស្គាល់តាម៉ុក?

យុន :	គេនិយាយថាតានឹងឈ្មោះតាម៉ុកៗ ។

ធានី :	រូបរាងគាត់យ៉ាងម៉េច?

យុន :	ខ្ញុំអត់បានឃើញទេ ប៉ុន្តែពូតែគេថាអូ! តាម៉ុកចុះមកហើយធ្វើរបៀបសម័យ៣ឆ្នាំទៀត ហើយ គេតវ៉ាគេប្រឆាំង ។

ធានី :	លែងបានធ្វើ គ្រាន់តវ៉ាប្រឆាំង?

យុន :	បាទ! អត់ធ្វើ ។

ធានី :	មានអីជាតំណាងយើងប្រកែកយកទ្រព្យសម្បត្តិឯកជនមកដាក់ចូលរួម?

យុន :	គ្មានអីជាតំណាងផង គ្រាន់គេប្រឆាំង ថាគេមិនព្រមទេ គេខំរកស៊ីមកហើយឯងធ្វើអីចឹង មានតែថាសម្លាប់ប្រជាជនឯងទៀតហើយ ។ បើប្រជាជនមិនខំរកអីចឹង មានរទេះគោ មាន កង់មានអីម៉ូតូ ដល់នេះគេថាមិត្តឯងប្រឆាំងនឹងអង្គការ ។ ដល់ប្រជាជននាំគ្នាតវ៉ាប្រឆាំង ច្រើនអីចឹងទៅ គេថាត្រូវប្រឆាំង កាលសម័យ៣ឆ្នាំលំបាកម៉ាសារ រហូតមកដល់នឹងទៀត ធ្វើអីចឹងទៀត គេមិនសុខចិត្ត ។

ធានី :	អ្នកណាគេឡើងប្រឆាំង?

យុន :	គេប្រឆាំងជាទូទៅ និយាយតៗគ្នា ដល់អីចឹងពូទៅត្រង់ណាក៏ពូប្រជាជននិយាយអីចឹង គេ អត់ហ៊ាន ។

ធានី :	ចូលសមាហរណកម្មឆ្នាំណា?

យុន :	សមាហរណកម្មដូចភ្លេចហើយ ឆ្នាំ៩០ប៉ុន្មាន ៩៦ ឬ៩៤ ។

ធានី :	៩៦ ឬ៩៧?

យុន :	ឆ្នាំ៩៦ទេដឹង ៩៦នឹងឯង ខ្ញុំមិនបានចាំដែរ មិនដឹងប៉ុន្មានទេ ។

ធានី :	ម៉េចបានពូដឹងថាអានឹងសមាហរណកម្ម?

យុន :	ចុះបើសម្តេចហ៊ុនសែនមក គាត់ជិះយន្តហោះចុះមក ។

ធានី :	ហើយអ្នកណាគេទៅទទួលគាត់?

យុន :	ប្រជាជនអស់នឹង ។

ធានី :	ទាំងអស់គ្នា?

យុន ៖ ទាំងអស់គ្នា ទាំងមេទាំងអី ។

ធានី ៖ មេនឹងអ្នកណាគេ?

យុន ៖ ទាំងមេៗកងទ័ពនៅសព្វថ្ងៃ ។

ធានី ៖ អ្នកណាគេ?

យុន ៖ មេកងទ័ពនឹងលោកសុខ ភាព ។

ធានី ៖ សុខ ភាពនឹងគាត់អ្នកទៅទទួល?

យុន ៖ បាទ! ហៅប្រជាជនទៅទទួលទាំងអស់ ។

ធានី ៖ សុខ ភាពនឹងគាត់មេកងទ័ពនឹង?

យុន ៖ បាទ!

ធានី ៖ ចុះលើ សុខ ភាពនឹង មានអ្នកណាគេទៀត?

យុន ៖ គ្មានទេ មានតែគាត់នឹងលើ ។

ធានី ៖ គេដាក់ម៉ាឡៃនឹងជាតំបន់អី?

យុន ៖ អត់ដឹង ។

ធានី ៖ ហើយពូទៅទទួលគាត់ដែរ?

យុន ៖ បាទ!

ធានី ៖ បានឃើញ?

យុន ៖ បាន ។

ធានី ៖ បានឃើញទាំងលោកសុខ ភាព ទាំងនាយករដ្ឋមន្ត្រី?

យុន ៖ បាន ។

ធានី ៖ កាលនឹងពូនៅកន្លែងណា កន្លែងទទួល?

យុន ៖ កន្លែងទទួលនៅសាលារៀន កន្លែងសាលាស្រុករាល់ថ្ងៃ ។

ធានី ៖ ដែលធ្លាប់ព្រឿងសារតាំង?

យុន ៖ សារតាំងនឹងនៅក្នុង ។

ធានី ៖ ថាសារតាំងនឹងម៉េច?

យុន ៖ សារតាំងនឹងកន្លែងសម្តេច ។

ធានី ៖ សម្តេចម៉េច?

យុន ៖ សម្តេចសីហនុ សីហមុន្នីនៅ ។

ធានី ៖ កន្លែងនឹងម៉េច?

យុន ៖ កន្លែងនឹងស្តេចនៅ ។

ធានី ៖ ម៉េចបានគេហៅសារតាំង?

យុន ៖ គេដាក់ឈ្មោះថាកន្លែងសារតាំង កន្លែងទទួលភ្ញៀវ កន្លែងស្តេច ពេលភ្ញៀវបរទេសគេមក មកជួបស្តេចនៅកន្លែងនឹង ព្រោះសីហមុន្នីនៅ ។

ធានី ៖ ពេលណា ឆ្នាំ?

យុន ៖ សីហមុន្នីមកនៅឆ្នាំ៩១ ៩២ ។

ធានី ៖ ចុះសម្តេចយើងមកនៅពេលណា?

យុន ៖ សម្តេចមកនៅឆ្នាំ៩៣ ។

ធានី ៖ គាត់មកនៅនឹងធ្វើអី?

យុន ៖ គាត់មកនៅជាមួយប្រជាជន ដល់ឆ្នាំ៩២គាត់ឡប់ទៅវិញ ។

ធានី ៖ ពូធ្លាប់ឃើញគាត់ទេ?

យុន ៖ ឃើញ ។

ធានី ៖ ពេល៩១ ៩២នឹង?

យុន ៖ បាទ!

ធានី ៖ គាត់ស្លៀកពាក់ម៉េចទៅ?

យុន ៖ ស្លៀកពាក់ធម្មតា អាខោអាវគគីរ ខោអាវទាហានថៃ អាខោអាវគគីរស ខោមិនខោអាវមិនអាវ ។ ពេលព្រឹកឡើងគាត់មកធ្វើការជាមួយពួកខ្ញុំ ស្រោចស្តែស្រោចអី គាត់មក ។

ធានី ៖ មកមើល មកធ្វើ?

យុន ៖ មកធ្វើតែម្តង មិនឲ្យគាត់ធ្វើ គាត់ថាធ្វើគាត់ប្រជាជន គាត់ស្នេហាជាតិស្នេហាប្រជាជន ។ ។

ធានី ៖ ហើយពូធ្លាប់និយាយជាមួយគាត់ដែរ?

យុន ៖ ខ្ញុំធ្លាប់និយាយដែរ ។

ធានី ៖ គាត់និយាយជាមួយពូរឿងអី?

យុន ៖ គាត់និយាយដូចខ្ញុំធម្មតា គាត់មិនឲ្យថាហៅព្រះអង្គហៅអី ។

ធានី ៖ គាត់ប្រាប់ពូដែរ?

យុន ៖ ប្រាប់ៗប្រជាជនទាំងអស់ ។

ធានី ៖ ពូដឹងថាគាត់ស្តេចដែរ?

យុន ៖ ដឹង ចុះមេប្រធានភូមិគេប្រាប់ ។

ធានី ៖ គាត់ហូបអី?

យុន ៖ ហូប ហើយរបស់គេផ្ញើពីបរទេសមក គាត់អត់ហូបទេ យកមកចែកឲ្យយើងហូបទាំងអស់គ្នានឹង ។

ធានី ៖ គាត់ធ្វើការដូចប្រជាជន?

យុន ៖ ដូចរាស្ត្រធម្មតា អ្នកភាគច្រើនគេអត់មានអ្នកណាស្គាល់ទ័ពអី អត់មានស្គាល់ថាគាត់ជាស្ដេចទេ ។

ធានី ៖ ចុះម៉េចបានពូស្គាល់?

យុន ៖ ចុះខ្ញុំនៅជាប់នៅកន្លែងមន្ទីរនៅនឹង ។

ធានី ៖ នៅក្បែរសារតាំង?

យុន ៖ បាទ!

ធានី ៖ ៨២ ៨៣ពូនៅកន្លែងនឹង?

យុន ៖ បាទ! នៅជិតគ្នា ។

ធានី ៖ ផ្ទះនៅក្បែរគាត់?

យុន ៖ បាទ!

ធានី ៖ ក្រែងពូពិការជើង?

យុន ៖ ពិការជើងមិនទាន់គាត់ផង គ្រាន់តែបែកឆ្អឹងដើរបាន ។

ធានី ៖ ពូធ្វើចំការដាំដំណាំ?

យុន ៖ បាទ! ដំណាំយើង ប្រកបអាជីវកម្ម ។

ធានី ៖ ដាំអី?

យុន ៖ ដាំស្ពៃ ។

ធានី ៖ ដាំនឹងដើម្បីហូបខ្លួនឯង?

យុន ៖ ហូបខ្លួនឯង ។

ធានី ៖ មានឲ្យសហករណ៍?

យុន ៖ អត់ទេ គ្មានសហករណ៍គ្មានអីទេ ។

ធានី ៖ គាត់មកជួយពូ?

យុន ៖ ចុះនៅជិតគ្នា គាត់ចុះជាប់ជាមួយប្រជាជន ។

ធានី ៖ គាត់មកជួយតែពូទេ?

យុន ៖ អត់ទេ ជួយទូទៅ ឲ្យតែគាត់ដើរទៅឃើញអ្នកណាធ្វើអីទៅធ្វើដែរ ឃើញកាប់ដីគាត់យកចបកាប់ដីដែរ ។

ធានី ៖ កាប់ម៉ាហត់?

យុន ៖ ដល់យើងឈប់ បានគាត់ឈប់ដែរ ។

ធានី ៖ មានអ្នកណាដើរតាមគាត់ទេ?

យុន ៖ មានកងការពារ ។

ធានី ៖ ប៉ុន្មាននាក់?

យុន ៖ មាន៣-៤នាក់ ។

ធានី ៖ គេធ្វើដែរ ឬមួយគ្រាន់ឈរមើល?

យុន ៖ ធ្វើទាំងអស់គ្នានឹង ហើយពួកអាការពារនឹង តែឃើញគាត់ការពារនឹងតែឃើញគាត់កាប់ដី កាប់អីនឹងហើយ ពួកគេធ្វើដែរ ។

ធានី ៖ តែគាត់មកកន្លែងណាស្រួលកន្លែងនឹង?

យុន ៖ ហ្នឹងហើយ គាត់ស្រួលគាត់ស្លូត ។

ធានី ៖ ក្រោយមកសម្តេចយើងគាត់មកដែរ?

យុន ៖ ក្រោយមកសម្តេចសីហនុគាត់មក ដូចថាកូនគាត់នៅនឹង គាត់បង្កើតដាក់កន្លែងសារតាំង សម្តេចសីហនុជាអ្នកដាក់ឈ្មោះ ។

ធានី ៖ អ្នកដាក់ឈ្មោះសារតាំងនឹង?

យុន ៖ បាទ!

ធានី ៖ ដាក់ឆ្នាំ ៨៤ ៨៣នឹង?

យុន ៖ ឆ្នាំ៨២ ។

ធានី ៖ សម្តេច៨២ ៨៣?

យុន ៖ គាត់មិនដឹងដាក់ឆ្នាំប៉ុន្មានផង ខ្ញុំមិនដឹងដែរ ។

ធានី ៖ គាត់មកដល់ដំបូងដាក់ភ្លាម ឬមួយមកដល់ដាក់យូរហើយ?

យុន ៖ កន្លែងនឹង ទាល់តែសម្តេចសីហនុមក ។

ធានី ៖ មកបានដាក់?

យុន ៖ បាទ!

ធានី ៖ សម្តេចសីហមុន្នីមកមុន?

យុន ៖ មកមុន ។

ធានី ៖ គាត់នៅនឹងធម្មតា?

យុន ៖ ធ្វើធម្មតា ។

ធានី ៖ កាលពេលនោះមុំពូមានអ្នកផ្សេងទៀតដូចពូ?

យុន ៖ អូ! មនុស្សច្រើនរាប់រយ ។

ធានី ៖ ធ្វើចំការនៅក្បែរៗវាលៗកន្លែងផ្ទះគាត់ស្នាក់នៅ ឬនៅឆ្ងាយ?

យុន ៖ មិនមែនធ្វើចំការអីយើងដាំស្ពៃដាំអី បន្លែហូប ។

ធានី ៖ ដាំនៅមុខផ្ទះ?

យុន ៖ បាទ! តាមមាត់អូរ ។

ធានី ៖ កាលនឹងផ្ទះពូនៅទិសខាងណានៃសារគាំងនឹងបើគិតពីឥឡូវ?

យុន ៖ ផ្ទះខ្ញុំនៅឆ្ងាយដែរ ពីនឹងមកនេះ បើផ្ទះខ្ញុំនៅមាត់អូរ ។

ធានី ៖ ប្រហែល២គីឡូ?

យុន ៖ មិនមែនទេ ប្រហែល៤០០-៥០០ម៉ែត្រ ។

ធានី ៖ គាត់ឃើញគាត់ចេះជួយ?

យុន ៖ គាត់ចេះដើរទៅ ថ្ងៃលនឹងគាត់ដើរលេង មិនថាអ្នកណាឲ្យតែឃើញ គាត់អត់ចេះប្រកាន់ ។

ធានី ៖ ពូដឹងហេតុអីបានគាត់នៅនឹង?

យុន ៖ អត់ដឹង ខ្ញុំមិនដឹងដែរ រឿងនយោបាយរបស់គេ ។

ធានី ៖ អត់ដឹងមូលហេតុ?

យុន ៖ អត់ដឹង ។

ធានី ៖ គ្រាន់តែឃើញគាត់មក ពូរីករាយនឹងបានជួបគាត់?

យុន ៖ បាទ!

ធានី ៖ ដល់ពេលសម្តេចសីហនុមកក៏គាត់អត់ដឹងថាមកធ្វើអីដែរ?

យុន ៖ បាទ!

ធានី ៖ ដល់ពេលក្រោយៗទៀត ឲ្យតែមានភ្ញៀវបរទេសមក គឺយកកន្លែងនឹងយកធ្វើជាការណាត់របស់ភ្ញៀវបរទេស?

យុន ៖ បាទ!

ធានី ៖ មានភ្ញៀវច្រើនទេ?

យុន ៖ ច្រើនមានបារាំង ជប៉ុន ចិន គ្រប់ប្រទេស ។

ធានី ៖ ហើយអ្នកណាគេអ្នកទៅទទួលគាត់?

យុន ៖ មិនដឹងដែរ មានប្រជាជន ។

ធានី ៖ អ្នកដែលធំត្រូវទទួលអញ្ជើញគាត់មកដល់?

យុន ៖ ខ្ញុំមិនសូវដឹងដែររឿងផ្ទៃក្នុងគេ ។

ធានី ៖ គ្រាន់ពូបានឃើញពីចំងាយ?

យុន ៖ បាទ!

ធានី ៖ ដល់ពេលពូៗនៅក្បែរនឹង ដល់ពេលក្រោយមក ម៉េចបានពូមកនៅនេះ?

យុន ៖ ខ្ញុំ ចុះដល់ពេលខ្ញុំរៀបការគ្រួសារ ខ្ញុំមកនៅនឹងទៅ ។

ធានី ៖ លែងទៅនៅក្បែរនឹងហើយ?

យុន ៖ ឈប់ហើយ ។

ធានី ៖ ចុះពេលនឹងសម្តេចសីហនុគាត់លែងយាងមកហើយ?

យុន ៖ ឈប់ហើយ ។

ធានី ៖ បាត់រហូត?

យុន ៖ រហូត ។

ធានី ៖ ពូដឹងថាគាត់សម្តេចសីហមុន្នី?

យុន ៖ បាទ!

ធានី ៖ កូនរបស់អ្នកណាគេៗ?

យុន ៖ ចុះគាត់និយាយ ។

ធានី ៖ គាត់និយាយប្រាប់ពូ?

យុន ៖ បាទ!

ធានី ៖ និយាយប្រាប់ពូផ្ទាល់មាត់?

យុន ៖ ហ្នឹងហើយ ។

ធានី ៖ តែម្នាក់ឯង?

យុន ៖ អូ! ឲ្យតែអ្នកស្គាល់ទាំងអស់ ដោយឡែកអ្នកនៅឆ្ងាយៗដូចទ័ពនៅមុខអត់ស្គាល់ទេ បើថាអ្នកនៅជុំវិញដូចខទាហរណ៍ថាភូមិនឹង ស្គាល់គាត់ដឹងៗតែម្នាក់ៗចេះតគ្នា ប៉ុន្តែមិនមែនជាចំហទេ គ្រាន់ស្គាល់គ្នា ។

ធានី ៖ ចុះមានអ្នកផ្សេងដូចពូប៉ុន្មាននាក់?

យុន ៖ ថាដឹងទាំងអស់នឹង ។

ធានី ៖ ចង់និយាយថាឥឡូវគាត់រស់នៅភូមិណា?

យុន ៖ មិនដឹងណាណៃបែកគ្នាអស់ ខ្ញុំមិនដឹងដែរ ។

ធានី ៖ ដឹងតែពូ អ្នកផ្សេងទៀតដែលគាត់រស់នៅភូមិណា រយៈពេលម៉ាឆ្នាំ២ឆ្នាំ?

យុន ៖ អត់ដឹងមិនដឹងថាគាត់ធ្វើអីៗ ។

ធានី ៖ មានសង្គ្រាមជាមួយវៀតណាមរត់ទៅរត់មក គាត់(សម្ដេចសីហមុនី) នៅនឹងគាត់អត់ខ្វាច?

យុន ៖ អត់ ដូចប្រជាជនយើងធម្មតា គាត់ធ្វើ ។

ធានី ៖ វៀតណាមកាលនឹងមិនទាន់វៃដល់?

យុន ៖ អត់ទាន់ ទើបនៅខ្វាវ ។

ធានី ៖ ចូលទៅជរំតាង៉ុកក៏អត់ដែលឃើញគាត់ទៅមើលពួកពូដែរ?

យុន ៖ គាត់ទៅបរទេស ។

ធានី ៖ ពូរកនឹកមើល មានមីងឬពូណាដែលនៅក្បែរ ពូនិយាយមានមេភូមិគាត់ដឹង?

យុន ៖ គាត់ស្លាប់ហើយ ។

ធានី ៖ គាត់ឈ្មោះអីគេដែរស្លាប់នឹង?

យុន ៖ ថេន ។

ធានី ៖ មេភូមិនេះ?

យុន ៖ បាទ!

ធានី ៖ មករស់នៅនឹង ឬមួយថ្ងៃ ពីរថ្ងៃ?

យុន ៖ ម៉ាថ្ងៃពីរថ្ងៃ ។

ធានី ៖ ហើយពេលនឹងកូនគាត់ទៅដែរ?

យុន ៖ ទៅ ។

ធានី ៖ អ្នកផ្សេងទៀតដឹងទេ?

យុន ៖ ខ្ញុំមិនសូវដឹងដែរ ព្រោះខ្ញុំជាប្រជាជនជាធម្មតា ខ្ញុំមិនសូវដឹងរឿងគេ ។

ធានី ៖ នេះយើងដឹងដោយចៃដន្យ?

យុន ៖ បាទ! ដឹងដោយចៃដន្យ ។

ធានី ៖ ចិត្តរបស់ពូផ្ទាល់តាំងពីសម័យមុន រហូតមកដល់សម័យឥឡូវការរស់នៅ តើពូគិតថាការរស់នៅពីរបបមុន ឥឡូវមួយណាស្រួលជាង តាំងពីជំនាន់ពូធ្វើទាហាន រហូតដល់សម័យ៣ឆ្នាំបន្ទាប់មកទៀតឆ្នាំ៧៩ រហូតមកដល់ឥឡូវ?

យុន ៖ ធ្វើម៉េចដូចសម័យនេះ យើងមានសិទ្ធិសេរីភាព ការរកទទួលទាននេះយើងមាន យើងចង់ធ្វើស្អីក៏បានឲ្យតែស្របក្នុងច្បាប់កុំឲ្យខុសច្បាប់ ។

ធានី ៖ ពូគិតថាសម័យនេះល្អជាង?

យុន ៖ បាទ! យើងប្រកបអាជីវកម្មយើងរកបានគ្រប់បែបយ៉ាងទាំងអស់ ចៀសវាងតែយើងធ្វើខុសច្បាប់ ។

ធានី ៖ នៅសម័យ៣ឆ្នាំ ពូដែលធ្លាប់ជួយអ្នកដទៃទេ?

យុន ៖ ជួយរបៀបម៉េច?

ធានី ៖ ជួយឲ្យជាចំណីអាហារ ជួយឲ្យរួចជីវិត ឬជួយជាថ្នាំសង្កូវ ។

យុន ៖ ខ្ញុំមិនដែលផង គ្រាន់តែថាគ្រាន់តែជួយធ្វើការគាត់ ដូចថាគាត់ពេលដកច្រូតជួយគាត់ ។

ធានី ៖ ពេលគាត់កំពុងស្ទូងដក មានឈឺ ខ្យល់គរ ពូជួយមើល?

យុន ៖ កម្រដែលមាន មិនដែលបានជួបផង ។

ធានី ៖ ការផ្សះផ្សាមានន័យថាធ្វើឲ្យត្រូវរ៉ូវគ្នា ធម្មតាមនុស្ស២នាក់ត្រូវការផ្សះផ្សា ដើម្បីឲ្យគាត់ត្រូវរ៉ូវគ្នាវិញ ។ ចង់សួរពូថាការផ្សះផ្សានឹង គួរនៅជិត ឬនៅឆ្ងាយល្អជាង?

យុន ៖ ការផ្សះផ្សានឹងមានតែយើងនៅឲ្យជិតគ្នា ដើម្បីយើងដឹងចិត្តគំនិតគ្នា មានធុរៈអ្វីដល់ម្នាក់នឹងយើងជួយយកអសារគ្នាទៅ មានគ្រោះថ្នាក់ ។ ដល់អីចឹងគេថាយើងស្គាល់គ្នា ជួយគ្នា គ្មានយកអ្នកឆ្ងាយមកការពារយើងបាន មានអ្នកនៅជិតនឹងឯង ពេលមានអាសន្ននឹងមានអ្នកជិតខាងនឹងជួយគ្នា ។

ធានី ៖ ចុះពូមានរូបថតចាស់?

យុន ៖ គ្មាន មិនដែលមានរូបថតអីផង ។ គ្មានអ្នកណាដឹងគាត់(សម្តេចសីហមុនី) ពាក្យថាស្គាល់គ្នាស្គាល់ថាតគ្នា ។

ធានី ៖ ពូឥឡូវដឹងថាគាត់បានឡើងគ្រោងរាជធ្វើជាស្តេចគ្រោងរាជ?

យុន ៖ ខ្ញុំដឹងខ្ញុំមើលឃើញតាមទូរទស្សន៍ស្គាល់ ។

ធានី ៖ កាលដំបូងពូដឹងថាគាត់ ស្គាល់ឈ្មោះគាត់?

យុន ៖ ស្គាល់ ចុះបើមេភូមិគាត់ប្រាប់ អ្នកនៅកងការពារប្រាប់ ។

ធានី ៖ គាត់អត់អញ្ជើញមកនេះ?

យុន ៖ អត់ដែរ ។

ធានី ៖ ចុះពូមានអីចង់សួរ ឬក៏មានអីចង់ប្រាប់វិញ?

យុន ៖ អត់មាន ។

ធានី ៖ អរគុណពូច្រើន ។

«ចប់»